**ឯកសារស្រាវជ្រាវ**

គណៈកម្មការទី៦ ទទួលបន្ទុកនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា

# ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ


ស្រាវជ្រាវដោយ៖ លោកស្រី **ស៊ូ សោភា**

ដោយមានការចូលរួមពី៖ កញ្ញា **ទិត្យ ស៊ីដែត**



ខែមិថុនា ឆ្នាំ២០១៥

**វិទ្យាស្ថានសភាកម្ពុជា**

# កំណត់សម្គាល់

វិទ្យាស្ថានសភាកម្ពុជា (វ.ស.ក)គឺជាស្ថាប័នឯករាជ្យមួយដែល ផ្តល់ការគាំទ្រដល់សភាកម្ពុជា តាមរយៈការផ្តល់នូវឯកសារស្រាវជ្រាវទៅតាមសំណើរបស់សមាជិក-សមាជិកា និងគណៈកម្មការជំនាញរបស់រដ្ឋសភា-ព្រឹទ្ធសភា ដែលមានការវិភាគទៅលើបញ្ហាដែលកំពុងតែកើតមាននៅពេលបច្ចុប្បន្ន និងដែលអាចនឹងកើតឡើងនាពេលអនាគត លើប្រធានបទការរៀបចំច្បាប់ និងគោលនយោបាយសាធារណៈ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានផ្សេងៗដែលពាក់ព័ន្ធនឹងការងារសភា និងការងារមណ្ឌល ឬ ភូមិភាគរបស់សមាជិក-សមាជិការសភា ក៏ប៉ុន្តែ រាល់អត្ថន័យដែលមាននៅក្នុងឯកសារទាំងនេះមិនមែនតំណាង ឬឆ្លុះបញ្ចាំងអំពី ទស្សនះផ្ទាល់របស់វិទ្យាស្ថានសភាកម្ពុជា សភា ឬសមាជិក-សមាជិកាណាម្នាក់នោះឡើយ។

ខ្លឹមសារនៃឯកសារទាំងនេះមានកំណត់នូវកាលបរិច្ឆេទរៀបចំច្បាស់លាស់ និងអាចប្រើប្រាស់សម្រាប់តែជាឯកសារយោងប៉ុណ្ណោះ។ ឯកសារទាំងនេះមិនមានគោលបំណងផ្តល់ប្រឹក្សាផ្នែកច្បាប់ ឬទៅលើគោលនយោបាយណាមួយឡើយ ហើយក៏មិនបានធ្វើការសិក្សាឲ្យបានគ្រប់ប្រធានបទ ឬរាល់ខ្លឹមសារលម្អិតដែលពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើងនោះដែរ។

ខ្លឹមសារនៃឯកសារស្រាវជ្រាវនេះស្ថិតក្រោមច្បាប់ជាធរមានរបស់កម្ពុជា និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីសិទ្ធិអ្នកនិពន្ធ។ រាល់ការរៀបចំឡើងវិញដោយដកស្រង់នូវផ្នែកណាមួយ ឬខ្លឹមសារទាំងស្រុងនៃឯកសារស្រាវជ្រាវនេះ ត្រូវមានការអនុញ្ញាតពី វិទ្យាស្ថាន។

រក្សាសិទ្ធិ ឆ្នាំ២០១៥ វិទ្យាស្ថានសភាកម្ពុជា (ក.ស.វ)។

មាតិកា


បញ្ជីរូបភាព....................i

ខ្លឹមសារសង្ខេប....................ii

I. សេចក្តីផ្តើមពីការដោះស្រាយវិវាទ .................... 1

១. ការដោះស្រាយតាមរយៈតុលាការ .................... 1

២. ការដោះស្រាយតាមរយៈការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR).................... 1

២ .១.ការចរចា(Negotiation).................... 3

២ .២.សន្ទានកម្ម(Mediation).................... 3

២ .៣. ការផ្សះផ្សា(Conciliation) .................... 3

២ .៤. មជ្ឈត្តកម្ម(Arbitration).................... 3

II. ស្ថានភាពជាប្រវត្តិសាស្ត្រ និងស្ថានភាពបច្ចុប្បន្នចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា.................... 6

១. បទពិសោធន៍ជាទំនៀមទំលាប់ និងប្រវត្តិសាស្ត្រ .................... 6

២. កម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ.................... 7

៣. ការវិវត្តន៍នៃក្រមខ័ណ្ឌច្បាប់ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់ច្បាប់ និងយុត្តិធម៌សម្រាប់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ.................... 9

III. ការគ្រប់គ្រងជម្លោះនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ .................... 11

១. ថ្នាក់ក្រោមជាតិ .................... 11

១.១ ថ្នាក់ឃុំ សង្កាត់ .................... 11

១.១.១. គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ .................... 11

១.១.២ មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ.................... 14

១.២ គណៈកម្មការសុរិយោដី .................... 16

១.២.១. គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ ........................................ 18

១.២.២. គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត........................................ 19

២. ថ្នាក់ជាតិ ........................................ 20

២.១. គណៈកម្មការសុរិយោដីថ្នាក់ជាតិ ........................................ 20

IV. បទពិសោធន៍ពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ........................................ 21

V. សេចក្ដីសន្និដ្ឋាន ........................................ 23

គន្ថនិទ្ទេស ........................................ 24

## បញ្ជីរូបភាព

រូបភាពទី១៖ទម្រង់ដ៏សំខាន់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ..................................... 4
រូបភាពទី២៖ ការប្រៀបធៀបប្រព័ន្ធ ADR (ដំណើរការអាជ្ញាកណ្តាល ) និងដំណើរការក្នុងតុលាការនៅប្រទេសអាមេរិក ........................................................................................................ 5
រូបភាពទី ៣៖ ការសន្មតដែលស្របទៅតាមយុត្តិធម៌តាមមូលដ្ឋាន និងដំណោះស្រាយក្រៅប្រព័ន្ធតុលាការ (Assumptions with respect to local justice and ADR) ..................................... 9
រូបភាពទី៤៖ ស្ថិតិនៃករណីបានទទួលដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់ .......... 13
រូបភាពទី៥៖ ស្ថិតិនៃប្រភេទជម្លោះ ............................................................................ 13
រូបភាពទី៦៖ ស្ថិតិនៃសំណុំរឿងដែលបានទទួលដោយមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ...16
រូបភាពទី៧៖ ស្ថិតិនៃប្រភេទជម្លោះដែលបានទទួលដោយមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ ........................................................................................................ 15
រូបភាពទី៨៖ ស្ថិតិនៃការវិវាទដីធ្លីដែលត្រូវបានតាំងលំនៅដោយគណៈកម្មការសុរិយោដី ២០០៣-២០០៩ ........................................................................................................ 18
រូបភាពទី៩៖ ដំណាក់កាលទាំង៥ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ .................. 20
រូបភាពទី១០៖ ចំនួនករណីដាក់ទៅកាន់អាជ្ញាធរជាតិដើម្បីដោះស្រាយវិវាទដីធ្លី ២០០៦-២០០៩.... 22

# ខ្លឹមសារសង្ខេប


ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺកើតមានជាប្រពៃណីជាយូរមកហើយនៅប្រទេសកម្ពុជា។ ដោយសារៈសំខាន់នៃដំណោះស្រាយក្រៅប្រព័ន្ធតុលាការ និងការធ្វើឲ្យប្រសើរឡើងនូវការទទួលបាននូវយុត្តិធម៌ រាជរដ្ឋាភិបាលបានធ្វើកាអនុវត្តសារជាថ្មី នូវទ្រឹស្តីនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធ ដោយដាក់ទ្រឹស្តីនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌។ យន្តការនេះត្រូវបានគេស្គាល់ថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ហៅកាត់ជាភាសាអង់គ្លេសថា ADR) ដែលត្រូវបានបង្កើតឡើងដើម្បីដោះស្រាយវិវាទជាច្រើននៅក្នុងបរិបទវិវាទគ្រួសារ ដីធ្លី ការងារ និងពាណិជ្ជកម្ម។

ឯកសារនេះ នឹងធ្វើការពិនិត្យមើលការអនុវត្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតសំខាន់ទៅលើគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និង មណ្ឌលសេវាកម្មយុត្តិធម៌ រួមទាំងគណៈកម្មការសុរិយោដីផង។ បទពិសោធន៍របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទាក់ទងនឹងការដោះស្រាយវិវាទការងារ ក៏ត្រូវបានយកមកពិនិត្យដើម្បីជាឧទាហរណ៍បញ្ជាក់ពីការអនុវត្តល្អ។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និងមណ្ឌលសេវាកម្មយុត្តិធម៌ គឺជាស្ថាប័នរដ្ឋដែលត្រូវបានបង្កើតឡើងដោយមានតួនាទីគ្រប់គ្រង និងកាត់បន្ថយទំនាស់នៅក្នុងមូលដ្ឋានដោយការធ្វើសន្ធានកម្ម និងផ្សះផ្សានូវរាល់ទំនាស់នៅពេលដែលភាគីយល់ព្រម។ ចាប់តាំងពីពេលចាប់ផ្តើមជារូបរាងគម្រោងសាកល្បងនៅឆ្នាំ២០០៦ មកដល់ពេលបច្ចុប្បន្ន គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និង មណ្ឌលសេវាកម្មយុត្តិធម៌ បានធ្វើការពង្រីកនូវសេវារបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការរបស់អ្នកប្រើប្រាស់។ ការងាររបស់គណៈកម្មាធិការ និងមណ្ឌលសេវាកម្មនេះ ត្រូវបានរាយការណ៍មកថាមានភាពជោគជ័យទោះបីជាមានកង្វះខាតនូវថវិកា និងភាពយឺតយ៉ាវនៃសេចក្តីព្រាងអនុក្រឹត្យស្តីពីការពង្រឹង និងពង្រីកយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនេះក៏ដោយ។

គណៈកម្មការសុរិយោដី គឺជាស្ថាប័នមួយទៀតដែលផ្តល់នូវសេវាផ្សះផ្សា និង សន្ធានកម្ម ដល់រាល់ទំនាស់ដីធ្លីដែលមិនបានចុះបញ្ជី។ឋានានុក្រមរដ្ឋបាលបីថ្នាក់របស់គណៈកម្មការនេះមានដូចជា គណៈកម្មកាសុរិយោដីក្រុងស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ គឺមានតួនាទីអនុវត្តនូវនីតិវិធីដែលមានចែងនៅក្នុងច្បាប់ និង

បទបញ្ញា។ ទោះបីជាការអនុវត្តនូវនីតិវិធីនោះមិនត្រូវបានអនុវត្តទៀងទាត់ក៏ដោយ ក៏ការបង្កើតនូវនីតិវិធីនេះគឺចាត់ទុកជាភាពជោគជ័យមួយរបស់គណៈកម្មការនេះដែរ។

បន្ទាប់ពីការចាប់ផ្តើមការងារនៅឆ្នាំ២០០៤ ក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺត្រូវបានចាត់ទុកថាជោគជ័យនៅក្នុងការផ្តល់នូវដំណោះស្រាយចំពោះវិវាទការងារតាមរយៈមជ្ឈត្តកម្ម។ ក្រុមប្រឹក្សានេះត្រូវបានអនុវត្តនូវតួនាទីកំណត់ដោយច្បាប់ និងបទបញ្ញា ដោយមានអំណាចអាចបកស្រាយច្បាប់ដោយឯករាជ្យ និងមានប្រសិទ្ធិភាព។

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និងមណ្ឌលសេវាកម្មយុត្តិធម៌ រួមទាំងគណៈកម្មការសុរិយោដីគឺអាចទទួលបាននូវអត្ថប្រយោជន៍នានា តាមរយៈការសិក្សាពីការអនុវត្តល្អប្រសើរពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយសារជំនាញ ឯករាជ្យភាព កេរ្តិ៍ឈ្មោះ និងប្រសិទ្ធភាពការងារ របស់ក្រុមប្រឹក្សានេះ ត្រូវបានកោតសរសើរដោយអ្នកប្រើប្រាស់ ភាគីពាក់ព័ន្ធ និងអង្គការពលកម្មអន្តរជាតិ។

## I. សេចក្តីផ្តើមអំពីការដោះស្រាយវិវាទ

### ១. ការដោះស្រាយតាមរយៈតុលាការ

តុលាការ គឺជាអង្គជនុំជម្រះក្តីដែលមានអំណាចក្នុងការដោះស្រាយជម្លោះទាក់ទងនឹងច្បាប់ ដោយធ្វើការពិនិត្យភាពត្រឹមត្រូវ នៃការអនុវត្ត និងបកស្រាយច្បាប់។[1] អំណាចតុលាការ គឺមិនត្រូវបានផ្តល់ទៅឲ្យអំណាចនីតិបញ្ញត្តិ ឬ នីតិប្រតិបត្តិ ដែលនេះមានន័យថា អំណាចតុលាការជាអំណាចដោយឡែកពីអំណាចទាំងពីរនោះ។[2] អង្គការតុលាការនៅក្នុងប្រទេសកម្ពុជាមានបីថ្នាក់ ដែលក្នុងនោះមានតុលាការខេត្តក្រុង (សាលាដំបូងរាជធានី-ខេត្ត) សាលាឧទ្ធរណ៍(ជាតុលាការលំដាប់ទីពីរបន្ទាប់ពីសាលាដំបូង) និងតុលាការកំពូល (ជាតុលាការដែលជាថ្នាក់ខ្ពស់បំផុត)។[3] តុលាការទាំងបីថ្នាក់នេះមានយុត្តាធិការក្នុងការសម្រេចនូវសំណុំរឿងគ្រប់ប្រភេទ រួមទាំង រឿងនីតិរដ្ឋបាលផងដែរ។[4] ប៉ុន្តែ មានតែសាលាដំបូងទេដែលអាចមានលក្ខណៈជំនាញទៅតាមរឿងក្តីដែលអាចមានជាតុលាការពាណិជ្ជកម្ម តុលាការការងារ និងតុលាការព្រហ្មទណ្ឌ។[5] យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋកម្ពុជាមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងផ្សេងៗដែល បណ្តឹងទាំងនេះស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការ។[6] នៅក្នុងប្រទេសកម្ពុជា ក្នុងឆ្នាំ២០០៣ តុលាការទទួលបានសំណុំរឿងចំនួន១២.០០០ រួមទាំងរឿងរដ្ឋប្បវេណី និងរឿងព្រហ្មទណ្ឌ។[7]

### ២. ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR)

ក្រៅពីការដោះស្រាយជម្លោះតាមរយៈតុលាការ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រមួយផ្សេងទៀត។ ការដោះស្រាយជម្លោះប្រភេទនេះ គឺជាយន្តការដែលប្រជាជនប្រើប្រាស់ជាជម្រើសដើម្បីដោះស្រាយជម្លោះនៅក្រៅប្រព័ន្ធយុត្តាធិការរបស់តុលាការ។[8] ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានចាប់ផ្តើមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ និង១៩៨០ និងទទួលបាននូវប្រជាប្រិយភាពចាប់ពីពេលនោះមក។[9] ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺត្រូវបានប្រើប្រាស់សម្រាប់ដោះស្រាយរឿងគ្រួសារ ជម្លោះជាមួយ

---

1 Nomira, Toyohiro. *Introduction to Civil Law* (JICA,2014), p. 188.

2 Cambodian Constitution, Article 130.

3 Law on the organization of courts, Article 3.

4 Cambodia Constitution, Article 128. Administrative case is when claimant goes against rulings made by administrative agencies (government) when implementing the public law. *See* more explanation in Kai HAUERSTEIN, "Aspects of Administrative Law and Its Reform in Cambodia" in The Cambodian Administrative Law, (Konrad-Adenauer-Stiftung, 2014).

5 Law on the organization of courts, Articles 4 and 5.

6 Cambodian Constitution, Article 39.

7 YRIGOYEN FAJARDO, Raquel Z., Rady, Kong and Phan, Sin, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples.* (UNDP-Ministry of Justice, 2005).

8 AUSTERMILLER, Steven, "Cambodian Alternative Dispute Resolution", in The Introduction to Law (Konrad-Adenauer-Stiftung, 2012) p. 183.

9 Lewis, Melissa, and McCrimmon, Les, "The Role of ADR Process in the Criminal Justice System: A view from Australia" (Paper presented at At ALRAESA Conference , Entebbe, Uganda 4-8 September, 2005) p. 1. Accessed from http://www.justice.gov.za/alraesa/conferences/2005uganda/ent_s3_mccrimmon.pdf.

អ្នកជិតខាង ក៏ដូចជាជម្លោះពាក់ព័ន្ធនឹងបរិស្ថាន ពាណិជ្ជកម្ម និងការងារ។[10] ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការមានជាច្រើនទម្រង់ ហើយទម្រង់ដែលត្រូវបានគេស្គាល់ជាទូទៅ គឺតាមរយៈមជ្ឈត្តកម្ម ការចរចា ការផ្សះផ្សា និងសន្ទានកម្ម។[11] មូលហេតុដែលនាំឲ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធនេះគឺ ទាក់ទងនឹងការចំណាយខ្ពស់ទាំងថវិកានិងពេលវេលាសម្រាប់រឿងក្តីនៅតុលាការ។[12] នេះមានន័យថា ពេលដែលសំណុំរឿងនៅតុលាការត្រូវចំណាយពេលយូរ ការចំណាយសម្រាប់មេធាវី និងសេវាតុលាការក៏កាន់តែខ្ពស់ដែរ។ ក្រៅពីការចំណាយ ការកកស្ទះសំណុំរឿងនៅតុលាការ ក៏ជាកត្តាដែលជម្រុញឲ្យមានការប្រើប្រាស់នូវយន្តការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការដែរ។[13] បច្ចុប្បន្ន ដោយសារតែបាតុភូតសកលភាវូបនីយកម្ម និងកំណើននៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ទម្រង់ថ្មីមួយនៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ត្រូវបានបង្កើតឡើងដែលហៅថា ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការផ្ទាល់តាមប្រព័ន្ធអេឡិចត្រូនិច(OADR)។ ការបង្កើតនេះមានគោលបំណងជម្រុញឲ្យភាគីវិវាទ ទំនាក់ទំនងគ្នាតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដើម្បីទទួលបាននូវកិច្ចព្រមព្រៀង។[14] យោងទៅតាមលោកJordan Goldberg[15] ទម្រង់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការតាមប្រព័ន្ធអេឡិចត្រូនិច គឺមានលក្ខណៈដូចគ្នាទៅនឹងទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការធម្មតា ប៉ុន្តែគ្រាន់តែប្រើប្រាស់ប្រព័ន្ធអ៊ិនធឺណេតជាមធ្យោបាយដើម្បីដោះស្រាយជម្លោះ។ ចំណុចដែលគួរឲ្យកត់សម្គាល់នៃការវិវឌ្ឍន៍របស់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ គឺជាការបញ្ចូលនូវវិធីដោះស្រាយនេះនៅក្នុងបរិបទនៃរឿងព្រហ្មទណ្ឌ។ ការប្រើប្រាស់នូវវិធីសាស្ត្រនេះនៅក្នុងរឿងព្រហ្មទណ្ឌ ហាក់បីដូចជាបាតុភូតថ្មីសម្រាប់ប្រទេសអឺរ៉ុប[16] និងប្រទេសអូស្ត្រាលី។[17] មូលហេតុនៃការប្រើប្រាស់ប្រព័ន្ធនេះដើម្បីដោះស្រាយវិវាទព្រហ្មទណ្ឌ ហាក់បីដូចជាទាក់ទងទៅនឹងការស្តារឡើងវិញនូវយុត្តិធម៌[18] ដែលផ្តោតសំខាន់ទៅលើជនរងគ្រោះដោយធ្វើការណែនាំដល់ជនល្មើសនូវគំនិតក្នុងការទទួលខុសត្រូវចំពោះជនរងគ្រោះ និងសហគមន៍។[19] កម្មវិធីជាច្រើនត្រូវបានបង្កើតឡើងដូចជាការធ្វើសន្ទានកម្មរវាងជនរងគ្រោះ និងជនល្មើស ការជួបជាមួយគ្រួសារ ឬក៏វេទិការវាងជនរងគ្រោះនិងជនល្មើស។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តការដោះស្រាយតាមវិធីសាស្ត្រនេះនៅក្នុងបរិបទរឿងព្រហ្មទណ្ឌ ហាក់បីដូចជាមិនអាចទទួលបាននូវជោគជ័យនោះទេ ដោយសារតែជនល្មើសប្រហែលជា

---

[10] *Ibid*., p. 2.

[11] Austermiller., “Cambodian Alternative Dispute Resolution”, p. 183.

[12] Goldberg, Jordan, “Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum” *Peperdine Dispute Resolution Law Journal*, 2014, pp. 2-4. Accessed from http://digitalcommons.pepperdine.edu/cgi/viewcontent.cgi?article=1261&context=drlj&sei-redir=1&referer=https%3A%2F%2Fscholar.google.com%2Fscholar%3Fhl%3Den%26as_sdt%3D0%2C5%26as_ylo%3D2014%26q%3DAlternative%2Bdispute%2Bresolution%2Bfree%2Bebook#search=%22Alternative%20dispute%20resolution%20free%20ebook%22.

[13] *Ibid*.

[14] *Ibid*.

[15] *Ibid*.

[16] Lewis and McCrimmon, “The Role of ADR Process in the Criminal Justice System: A view from Australia” p. 4.

[17] Lewis and McCrimmon, “The Role of ADR Process in the Criminal Justice System: A view from Australia” p. 4.

[18] This theory is different from conventional retributive justice, which believes that the act of the offender shall be treated as a violation against the State rather than against the victim.

[19] Lewis and McCrimmon, “The Role of ADR Process in the Criminal Justice System: A view from Australia” pp. 6-8.

មានអារម្មណ៍ស្ថិតនៅក្រោមគំនាបសង្កត់ដើម្បីឈានដល់ការព្រមព្រៀង ហើយទ្រឹស្តីនៃការរក្សានូវទំនាក់ទំនងរវាងជនល្មើស និងជនរងគ្រោះ មិនអាចអនុវត្តបានឡើយ។[20] ខាងក្រោមនេះ គឺជាការរៀបរាប់ពីទម្រង់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជាសង្ខេប។

### ២.១. ការចរចា ( Negotiation )

ការចរចាគឺជាវិធីដែលមនុស្សពីរនាក់ ឬក៏មួយក្រុម ប្រើប្រាស់ដើម្បីទទួលបាននូវអ្វីដែលពួកគេចង់បានពីភាគីម្ខាងទៀត។[21] ទម្រង់នេះមានលក្ខណៈសាមញ្ញក្នុងការដោះស្រាយជម្លោះរវាងមនុស្ស និងត្រូវបានប្រើប្រាស់សម្រាប់ជីវភាពប្រចាំថ្ងៃនៅក្នុងទំនាក់ទំនងគ្រប់ប្រភេទ។ ការទំនាក់ទំនងនេះអាចជារឿងផ្ទាល់ខ្លួន សង្គម វិជ្ជាជីវៈ ឬក៏ជាការជួបធម្មតា។ ពេលខ្លះអ្នកចរចាមិនបានដឹងថាខ្លួនកំពុងតែធ្វើការចរចានោះទេ។ ជាទូទៅការចរចាអាចធ្វើបានតាមវិធីសាស្ត្រជាច្រើន ដូចជាលក្ខណៈផ្លូវការ (តាមរយៈការប្រជុំ ឬក៏កិច្ចព្រមព្រៀងជាលាយលក្ខអក្សរ) ឬជាលក្ខណៈមិនផ្លូវការ (តាមរយៈទូរស័ព្ទ សារអេឡិចត្រូនិច និងសំបុត្រ)។

### ២.២. សន្ធានកម្ម ( Mediation )

សន្ធានកម្មគឺជាវិធីដែលអាចដោះស្រាយជម្លោះក្រៅពីតុលាការ។ សន្ធានការី(Mediators) ធ្វើការកោះហៅភាគីទាំងពីរ និងព្យាយាមធ្វើការដោះស្រាយនូវជម្លោះ ឬការទទួលបាននូវកិច្ចព្រមព្រៀងដែលភាគីទាំងពីរមានសិទ្ធិក្នុងការទទួលយក ឬបដិសេធ។[22]

### ២.៣. ការផ្សះផ្សា ( Conciliation )

ការផ្សះផ្សា គឺជាវិធីដែលភាគីទីបីដែលជាអ្នកផ្សះផ្សាជួបជាមួយនឹងភាគីជម្លោះដាច់ដោយឡែកពីគ្នា (ការជួបដាច់ដោយឡែកនេះគឺខុសគ្នាពីការធ្វើសន្ធានកម្ម) ដើម្បីព្យាយាមរកនូវការព្រមព្រៀងពីភាគីក្នុងការដោះស្រាយជម្លោះ។[23]

### ២.៤. មជ្ឈត្តកម្ម ( Arbitration )

មជ្ឈត្តកម្ម គឺជាវិធីដែលមានភាគីអព្យាក្រឹត្យ(មជ្ឈត្តករឬអាជ្ញាកណ្តាល៖ Arbitrator) ឬជាក្រុមមជ្ឈត្តករ ដែលធ្វើសវនាការលើភស្តុតាងរបស់ភាគីវិវាទទាំងពីរ ហើយចេញនូវសេចក្តីសម្រេចរបស់ខ្លួនដែលហៅថា *"សេចក្តីបង្គាប់អាជ្ញាកណ្តាល"*។[24] មជ្ឈត្តកម្មមានលក្ខណៈស្រដៀងគ្នាទៅនឹងតុលាការ ពីព្រោះមជ្ឈត្តករគឺត្រូវពិចារណានូវភស្តុតាងដែលភាគីវិវាទដាក់មក។ ទោះបីជាយ៉ាងណា នីតិវិធីនេះមានលក្ខណៈខុសពីតុលាការត្រង់ថា ភាគី

[20] *Ibid*.

[21] Austermiller, "Cambodian Alternative Dispute Resolution" p.183.

[22] *Ibid*., p. 185.

[23] YRIGOYEN FAJARDO, Raquel Z., Rady, Kong, and Phan, Sin, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples.* (UNDP-Ministry of Justice, 2005), p. 33.

[24] Austermiller, Steven M., *Alternative Dispute Resolution: Cambodia A Textbook of Essential Concept*( USAID, 2010), p. 137. Accessed from http://www.americanbar.org/content/dam/aba/directories/roli/cambodia/cambodia_adr_book_english_01_19_09.authcheckdam.pdf.

មានសិទ្ធិក្នុងការមិនចងកាតព្វកិច្ចទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាល ក៏ដូចជាការជ្រើសរើសនូវមជ្ឈត្តករ ទីកន្លែង និងពេលវេលាសម្រាប់ធ្វើមជ្ឈត្តកម្ម។[25] ភាពបត់បែននេះមិនមាននៅក្នុងតុលាការទេ។

រូបភាពទី១៖ទម្រង់ដ៏សំខាន់នៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

*ប្រភព៖ វិថីទៅកាន់យុត្តិធម៌៖ ការទទួលបាននូវយុត្តិធម៌ដែលផ្តោតទៅលើអ្នកក្រ ស្ត្រី និងជនជាតិភាគតិច, ក្រសួងយុត្តិធម៌ និងUNDP*

| | ការចរចា | សន្ទានកម្ម (Mediation) | ការផ្សះផ្សា (Conciliation) | អជ្ញាកណ្តាល/មជ្ឈត្តកម្ម (Arbitration) |
|---|---|---|---|---|
| **ភាគីចូលរួម** | ភាគីក្នុងជម្លោះ | ភាគីក្នុងជម្លោះ+សន្ទានការី(Mediator) | ភាគីក្នុងជម្លោះ + អ្នកផ្សះផ្សា(Conciliator) | ភាគីក្នុងជម្លោះ + អជ្ញាកណ្តាល/មជ្ឈត្តករ(Arbitrator) |
| **តួនាទីរបស់ភាគីទីបី** | ភាគីដោះស្រាយជម្លោះរបស់ពួកគេដោយខ្លួនឯង | សន្ទានការីព្យាយាមដើម្បីជួយសម្រួលដល់ដំណោះស្រាយ ពិចារណាពីផលប្រយោជន៍ និងសំណើរបស់ភាគី។ ភាគីទាំងសងខាងសម្រេចចិត្តទៅលើដំណោះស្រាយ។ | អ្នកផ្សះផ្សានាំយកសំណើទៅកាន់ភាគីដើម្បីដោះស្រាយជម្លោះរបស់ពួកគេ។ ភាគីទាំងសងខាងសម្រេច ចិត្តជាដំណោះស្រាយចុងក្រោយដោយមានជំនួយពីអ្នកផ្សះផ្សា។ | អាជ្ញាកណ្តាល/មជ្ឈត្តករបាននាំយកដំណោះស្រាយចំពោះករណីនេះ។ ភាគីទាំងសងខាងត្រូវតែគោរពការសម្រេចចិត្តនោះ។ |
| **ការផ្តួចផ្តើមដំណើរ** | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត | ការស្ម័គ្រចិត្ត (ឬតម្រូវដោយច្បាប់ ឬកិច្ចព្រមព្រៀងតំបូង) |
| **លទ្ធផល** | អាស្រ័យលើភាគី | អាស្រ័យលើការសម្រេចចិត្តរបស់ភាគីទាំងសងខាង | អ្នកផ្សះផ្សាស្នើសុំដំណោះស្រាយមួយ ប៉ុន្តែអាស្រ័យលើការទទួលយករបស់ភាគីទាំងសងខាង។ | អាស្រ័យលើការសម្រេចចិត្តរបស់អាជ្ញាកណ្តាល/មជ្ឈត្តករ |
| **លទ្ធផលអនុវត្តន៍** | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយ ប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | កិច្ចព្រមព្រៀងនេះគឺដូចជាកិច្ចសន្យាមួយប៉ុន្តែប្រសិនបើភាគីមួយមិនបានបំពេញតាមកិច្ចព្រមព្រៀង ភាគីម្ខាងផ្សេងទៀតត្រូវចូលទៅកាន់តុលាការ។ | សេចក្តីបង្គាប់អាជ្ញាកណ្តាល អាចនឹងត្រូវបានអនុវត្តតាមរយៈតុលាការ ឬ តាមធ្យោបាយផ្សេងទៀត។ |

*ប្រទេសកម្ពុជា។*

[25] *Ibid.*, pp. 139-140.

វិធីសាស្ត្រនៃការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះផ្តល់នូវសារៈសំខាន់យ៉ាងច្រើន ដែលធ្វើឲ្យការប្រើប្រាស់ប្រព័ន្ធនេះមានការកើនឡើង។ ផលប្រយោជន៍ចំបង គឺ វិធីសាស្ត្រនេះមានការពេញនិយមជាងតុលាការ ដោយសារតែ ការចំណាយពេលវេលា និងថវិកាមានលក្ខណៈសមស្រប និងមានប្រសិទ្ធិភាពជាងតុលាការ។ ការដោះស្រាយនៅតុលាការ គឺត្រូវចំណាយខ្ពស់ រីឯការចំណាយចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ជាពិសេសពេលដែលប្រើប្រាស់អាជ្ញាកណ្តាល/មជ្ឈត្តកម្ម) មានតម្លៃតែពាក់កណ្តាលនៃថ្លៃចំណាយនៅតុលាការប៉ុណ្ណោះ។[26] ឧទាហរណ៍ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ មិនតម្រូវឲ្យមានការធ្វើឯកសារច្រើននោះទេ ហេតុនេះការចំណាយក៏ទាប។[27] បន្ថែមពីលើនេះ ទម្រង់នៃការដោះស្រាយវិវាទទាំងបីនេះ (សន្ធានកម្ម ការផ្សះផ្សា និងមជ្ឈត្តកម្ម) ផ្តល់នូវភាពបត់បែនដល់ភាគីក្នុងការជ្រើសរើស នូវពេលវេលាដែលសមស្រប(សម្រាប់ភាគី និងភាគីអព្យាក្រឹត្យទីបី) ដោយមិនតម្រូវឲ្យភាគីត្រូវគោរពតាមពេលវេលាកំណត់ដោយតុលាការទេ។[28] អត្ថប្រយោជន៍មួយទៀតគឺថា ការដោះស្រាយរឿងក្តីនៅតុលាការ គឺហាក់បីដូចជាមានការយឺតយ៉ាវ និងបង្អែបង្អង់ ប្រសិនបើប្រៀបធៀបទៅនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធ។[29]

**រូបភាពទី២៖ ការប្រៀបធៀបប្រព័ន្ធ ADR (ដំណើរការអាជ្ញាកណ្តាល) និងដំណើរការក្នុងតុលាការនៅប្រទេសអាមេរិក**




*ប្រភព៖ វេទិកាមជ្ឈត្តកម្មថ្នាក់ជាតិ សំណុំរឿងមុនកិច្ចព្រមព្រៀងអាជ្ញាកណ្តាល៖ ប្រសិទ្ធិភាព និងអាចទទួលយកបាន*

ចំណុចចុងក្រោយ ការប្រើប្រាស់នូវការដោះស្រាយជម្លោះក្រៅប្រព័ន្ធ អាចរក្សានូវទំនាក់ទំនងរបស់ភាគីបាន។ ផ្ទុយនឹងសវនាការតុលាការដែលត្រូវធ្វើជាសាធារណៈ ផលប្រយោជន៍មួយសម្រាប់ភាគីនៃការដោះស្រាយជម្លោះ

[26] Paul, William G., "Arbitration vs.Litigation in Energy Cases, Presentation" (paper presented at the First Annual Energy Litigation Program, Hoston, Texas, November 7-8, 2002), p. 3. Accessed from http://www.adrforum.com/rcontrol/documents/ResearchStudiesAndStatistics/2002PaulArbitrationVLitigationInEnergyCases.pdf.

[27] Goldberg, "Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum", p. 5.

[28] *Ibid*.

[29] National Arbitration Forum, "Business-to-Business: Mediation/Arbitration vs. Litigation". Accessed from http://www.adrforum.com/users/naf/resources/GeneralCommercialWP.pdf.

ក្រៅប្រព័ន្ធគឺនីតិវិធីនៃការដោះស្រាយនេះត្រូវបានរក្សានូវភាពសម្ងាត់។[30] ការដោះស្រាយក្រៅប្រព័ន្ធនេះ ក៏ជាវេទិកាល្អមួយដែលធ្វើឲ្យបរិយាកាសមិនមានភាពតានតឹងខ្លាំង ដែលធ្វើឲ្យភាគីអាចពិភាក្សាពីការយល់ច្រលំ ឬចំណុចដែលមានវិវាទបាន។[31] ចំណុចទាំងអស់នេះជួយដល់ភាគីក្នុងការទទួលបាននូវដំណោះស្រាយឈ្នះ-ឈ្នះ ដែលអាចឲ្យភាគីទាំងពីរអាចរក្សានូវទំនាក់ទំនងល្អ។[32]

ការសិក្សាស្រាវជ្រាវនេះនឹងផ្តោតទៅលើបទពិសោធន៍ជាប្រវត្តិសាស្ត្រ និងប្រពៃណីក្នុងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា ដោយធ្វើការពិភាក្សាទៅលើការគ្រប់គ្រងវិវាទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងបទពិសោធន៍របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ឯកសារនេះក៏ធ្វើការពិភាក្សាទៅលើជំហររបស់រាជរដ្ឋាភិបាលទៅលើប្រព័ន្ធដោះស្រាយវិវាទក្រៅតុលាការផងដែរ។

## II. ស្ថានភាពជាប្រវត្តិសាស្ត្រ និងស្ថានភាពបច្ចុប្បន្នចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជា

### ១. បទពិសោធន៍ជាទំនៀមទម្លាប់ និងប្រវត្តិសាស្ត្រ

ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានអាយុកាលជាយូរណាស់មកហើយក្នុងប្រទេសកម្ពុជា។[33] ជារឿយៗប្រជាជនដោះស្រាយជម្លោះរបស់ពួកគេដោយផ្អែកទៅលើយន្តការប្រពៃណី និងវប្បធម៌ក្នុងសហគមន៍របស់ខ្លួន។[34] ការអនុវត្តនេះត្រូវបានគេហៅថាជា *"ការសម្របសម្រួល ឬការផ្សះផ្សា"* (ឧទាហរណ៍ការដោះស្រាយដោយចាស់ទុំនៅក្នុងស្រុក ឬប្រធានភូមិ)[35] ហើយដែលវិធីនេះគឺជា *"វប្បធម៌សន្តិភាព"* ដែលតែងមាននៅតាមមូលដ្ឋាន។[36] ទស្សនៈនេះមានន័យថា បុគ្គល និង/ឬ ក្រុមមនុស្សនៅក្នុងភូមិ ធ្វើការជាមួយគ្នាដើម្បីឆ្លើយតបទៅនឹងបញ្ហា (ដូចជាការធ្វើកិច្ចការប្រចាំថ្ងៃដោយមានការសហការគ្នាល្អ)[37] ហើយនឹងការចងក្រងជាគ្រួសារតូចមួយ។[38] រចនាសម្ពន្ធ័សង្គមនេះគឺផ្តោតសំខាន់ផងដែរទៅលើសុវត្ថិភាពរបស់សមាជិកនីមួយៗ។[39] ជាលក្ខណៈ

---

30 *Ibid*.

31 Goldberg, “Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum”, p. 14.

32 *Ibid*.

33 Phallack, Kong, “Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform”, in The Introduction to Cambodian Law, (Konrad-Adenauer-Stiftung, 2012) p. 12.

34 YRIGOYEN FAJARDO, Kong, and Phan, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples*, p. 1.

35 Ramage, Ian , et al., *Somroh Somruel & Violence Against Women,* (Domrei Research and Consulting, 2008), p. 1-4.

36 Hughes, Caroline, “An investigation of Conflict Management in Cambodian Villages: A review of the literature with Suggestions for Future Research”, (Cambodia Development Resource Institute (CDRI, 2001), p. 5-6. Accessed from http://www.cdri.org.kh/webdata/download/cpdpapers/cpd2e.pdf.

37 *Ibid*.

38 Luco, Fabienne, *Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices,* (UNECSO 2002.) pp. 16-17. Accessed from http://unesdoc.unesco.org/images/0015/001595/159544e.pdf.

39 Hughes, “An investigation of Conflict Management in Cambodian Villages: A review of the literature with Suggestions for Future Research”, p. 12.

ប្រពៃណី បងប្អូន ឬអ្នកជិតខាងដែលមានទំនាក់ទំនងជិតជិតគឺជាបុគ្គលទីមួយដែលភាគីមានវិវាទពឹងឲ្យមកជួយដោះស្រាយជម្លោះមុននឹងមានភាគីទីបីដែលឯករាជ្យ[40] តួអង្គសំខាន់ដែលដើរតួនាទីជាភាគីទីបី នៅក្នុងការសម្របសម្រួលគឺចាស់ទុំ ប្រធានភូមិ[41] ព្រះសង្ឃ អាចារ្យ និងមនុស្សសំខាន់ ឬល្បីដែលភាគីទុកចិត្ត។[42] ចាស់ទុំ ព្រះសង្ឃ និង អាចារ្យ ប្រើប្រាស់បទពិសោធន៍ និងចំណេះដឹងពីប្រពៃណី ដំបូន្មានរបស់ព្រះពុទ្ធនៅក្នុងការណែនាំ និងបង្រៀនមនុស្សដែលមានវិវាទគ្រួសារនិងវិវាទពាក់ព័ន្ធនឹងដីធ្លី។ ប៉ុន្តែ នៅពេលជម្លោះមានភាពធ្ងន់ធ្ងរ ជម្លោះនោះនឹងត្រូវបញ្ជូនទៅប្រធានភូមិ។[43] ប្រធានភូមិដែលមានការរៀនសូត្រផ្អែកលើប្រពៃណី និងដំបូន្មានព្រះពុទ្ធក្នុងការផ្តល់នូវដំណោះស្រាយ ចំណែកឯប្រធានភូមិដែលមិនបានរៀនសូត្រផ្តល់នូវដំណោះស្រាយដោយផ្អែកលើការយល់ឃើញផ្ទាល់ខ្លួន។[44] មុនឆ្នាំ១៩៧០ ព្រះមហាក្សត្រក៏ដើរតួនាទីជាភាគីទីបី ព្រោះព្រះអង្គធ្វើព្រះរាជសវនាការ ដែលប្រជាជនអាចយកជម្លោះរបស់ខ្លួនថ្វាយព្រះមហាក្សត្រជួយដោះស្រាយ។[45] ជាជាងដាក់ចេញនូវសេចក្តីសម្រេច ព្រះមហាក្សត្រផ្តល់នូវយោបល់ដែលមិនតម្រូវឲ្យភាគីត្រូវតែអនុវត្តទេ ។[46]

## ២. កម្ពុជាឆ្ពោះទៅកាន់ការដោះស្រាយវិវាទ

បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងប៉ារីស ខែតុលា ឆ្នាំ១៩៩១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវកំណែទម្រង់ប្រព័ន្ធតុលាការដោយបង្កើតនូវស្ថាប័នមានសមត្ថកិច្ចជាច្រើនដូចជា ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋក្នុងឆ្នាំ១៩៩៩ និង ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធម៌ក្នុងឆ្នាំ២០០២[47] គណៈរដ្ឋមន្ត្រីក៏បានធ្វើការអនុម័តទៅលើយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅក្នុងឆ្នាំ២០០៣ និងផែនការសកម្មភាពនៅក្នុងឆ្នាំ២០០៥។[48] គោលបំណងនៃយុទ្ធសាស្ត្រកំណែទម្រង់យុត្តិធម៌ និងតុលាការ គឺជាការបង្កើតនូវស្ថាប័នដែលមានកិត្យានុភាព និងស្ថេរភាពច្បាប់ និងយុត្តិធម៌ប្រកាន់ភ្ជាប់នូវគោលការណ៍សិទ្ធិបុគ្គល នីតិរដ្ឋ និងភាពចែកដាច់ពីគ្នានៃអំណាចនៅក្នុងប្រព័ន្ធប្រជាធិបតេយ្យ ដែលនេះគឺជួយជម្រុញដល់វិស័យឯកជនដើម្បីទទួលបាននូវភាពរីកចម្រើនសេដ្ឋកិច្ច។[49] ដើម្បីទទួលបាននូវភាពជោគជ័យក្នុងការអនុវត្តនូវគោលបំណងនេះ គោលដៅយុទ្ធសាស្ត្រប្រាំពីរត្រូវបានបង្កើត

---

40 Ramage, et al., "Somroh Somruel & Violence Against Women", pp. 3-4.

41 Luco, *Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices,* p. 31.

42 Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform" p. 13.

43 Luco, *Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices*. p.31.

44 *Ibid*.

45 Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform", p. 13.

46 *Ibid*.

47 Royal Decree on the Establishment of the Supreme Council of State Reform (1999), and Royal Decree No NS/RKT/0602/158 on the Establishment of the Council For Legal and Judicial Reform (2002). ថ្មីៗនេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងយុត្តិធm_ ត្រូវបានដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌ជំនួសវិញ។

48 *Ibid*.

49 *Ibid*.

ដែលក្នុងនោះ ការណែនាំនូវយុទ្ធសាស្ត្រដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការគឺជាគោលដៅទីប្រាំមួយ។[50] ចំណែកឯផែនការណ៍សកម្មភាពមានគោលបំណង «ស៊ើបអង្កេត បង្កើត និងពង្រឹងវិធីផ្សេងៗនៃការដោះស្រាយវិវាទក្រៅតុលាការ និងការដោះស្រាយវិវាទបែបប្រពៃណី។»[51]

មានមូលហេតុជាច្រើន ដែលជម្រុញឲ្យមានការកើនឡើងនូវការប្រើប្រាស់ប្រព័ន្ធដោះស្រាយវិវាទក្រៅផ្លូវតុលាការ ដោយក្នុងនោះមានដូចជា បញ្ហាទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាជនក្រីក្រ និងក្រុមជនដែលងាយរងគ្រោះ។[52] ប្រមាណ៨០ភាគរយ នៃប្រជាជនកម្ពុជាសរុប ១៣,៤លាននាក់ (ឆ្នាំ២០០៨) គឺជាអ្នករស់នៅជនបទ[53] ហើយជម្លោះតែងកើតឡើងចំពោះប្រជាជននៅតាមជនបទ ភាគច្រើន ជាជម្លោះរវាងបុគ្គល និងបុគ្គល ហើយភាគច្រើនប៉ះពាល់ ទៅដល់ អ្នកក្រីក្រ ស្ត្រី និងជនជាតិភាគតិច។ ជម្លោះទាំងនោះភាគច្រើនកើតឡើងក្នុងមូលដ្ឋាន ហើយទាក់ទងនឹងបញ្ហាហឹង្សាលើស្ត្រី ដីធ្លី និងព្រហ្មទណ្ឌ។[54] ប្រជាជននៅតាមតំបន់ជនបទយល់ឃើញថា ការធ្វើដំណើរទៅតុលាការមានចម្ងាយឆ្ងាយ ចំណាយច្រើន និងមាននីតិវិធីសាំញ៉ាំ។[55] មូលហេតុទាំងនេះជម្រុញឲ្យប្រជាជនមិនប្រើប្រាស់ប្រព័ន្ធតុលាការនៅក្នុងការដោះស្រាយវិវាទ។ បញ្ហានេះ គឺមកពីការកកស្ទះសំណុំរឿង និងកង្វះខាតធនធានមនុស្សនៅតុលាការ។[56] យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងយុត្តិធម៌របស់រាជរដ្ឋាភិបាលហាក់បីដូចជាផ្តោតសំខាន់ទៅលើមូលហេតុដែលថា តុលាការមិនគួរដោះស្រាយគ្រប់ជម្លោះដែលកើតឡើងនោះទេ ហើយដំណោះស្រាយក្រៅប្រព័ន្ធតុលាការគួរតែត្រូវបានយកចិត្តទុកដាក់។

រូបភាពទីបី ខាងក្រោមនេះបង្ហាញពីមធ្យោបាយយុទ្ធសាស្ត្រមួយចំនួន ដើម្បីឆ្លើយតបទៅនឹងឧបសគ្គជាក់ស្តែងដែលធ្វើឲ្យកម្ពុជាឈានទៅដល់ការទទួលយកនូវប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

---

[50] *Ibid.*

[51] YRIGOYEN FAJARDO, Kong,and Phan, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples,* p. 36.

[52] *Ibid.,* p. 2.

[53] "Cambodia." Accessed February 4, 2015, http://www.wpro.who.int/countries/khm/en/.

[54] YRIGOYEN FAJARDO, Kong, and Phan, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples,* p. 105.

[55] *Ibid.*, p. 1.

[56] *Ibid.*, pp. 1-2.

រូបភាពទី ៣៖ ការសន្មតដែលស្របទៅតាមយុត្តិធម៌តាមមូលដ្ឋាន និងដំណោះស្រាយក្រៅប្រព័ន្ធតុលាការ (Assumptions with respect to local justice and ADR)

| ឧបសគ្គជាក់ស្តែង | គោលការណ៍យុទ្ធសាស្ត្រ | អនុសាសន៍ |
|---|---|---|
| ១. ឧបសគ្គនៃភូមិសាស្ត្រ សេដ្ឋកិច្ច និងសង្គមវប្បធម៌ សម្រាប់ទទួលបាននូវសេវាប្រព័ន្ធតុលាការជាផ្លូវការ ។ | ការដោះស្រាយជម្លោះដែលមាននីតិវិធីងាយស្រួលឲ្យជួយកាត់បន្ថយភាពក្រីក្រ។ | ពង្រឹងយន្តការក្រៅផ្លូវការនៅតាមមូលដ្ឋានសម្រាប់ដោះស្រាយវិវាទ៖ ពោលគឺត្រូវនៅជិតកន្លែងដែលប្រជាជនរស់នៅ មិនធ្វើឲ្យពួកគាត់ចំណាយលុយច្រើន និងស្របជាមួយនឹងប្រពៃណីរបស់ប្រជាជន។ |
| ២. តុលាការមានសំណុំរឿងច្រើនឡើងៗ ប៉ុន្តែធនធាននៅមិនគ្រប់គ្រាន់។ | កង្វះខាតនៅក្នុងប្រព័ន្ធតុលាការជាផ្លូវការបណ្តាលឲ្យប៉ះពាល់ទៅដល់ឱកាសវិនិយោគសង្គម។ | ជាជាងចំណាយឲ្យមានធនធានបន្ថែមនៅក្នុងប្រព័ន្ធតុលាការ គួរតែមានការចំណាយប្រាក់បន្ថែមទៅលើប្រព័ន្ធ ADR ។ |
| ៣. តុលាការមិនអាចដោះស្រាយរាល់វិវាទដែលបានកើនឡើងនៅក្នុងសង្គមឡើយ។ ដោយឡែក នៅតាមតំបន់ជនបទមានប្រពៃណីដែលជាយន្តការសម្រាប់ការដោះស្រាយវិវាទ។ | តុលាការមាននីតិវិធីតាមជំនាញមុខងារ។ | តុលាការមិនគួរដោះស្រាយ គ្រប់វិវាទនោះទេ (គួរតែដោះស្រាយតែរឿងក្តីដែលមានជំនាញខ្ពស់)។ វិវាទមួយចំនួនគួរតែត្រូវបានដោះស្រាយនៅក្រៅតុលាការ។ |
| ៤. តុលាការអនុវត្តការកាត់ក្តីឲ្យមានអ្នកឈ្នះ និងអ្នកចាញ់។ | ការដោះស្រាយដោយសន្តិវិធីធ្វើឲ្យមានសន្តិភាពក្នុងសង្គម ។ | វិវាទភាគច្រើនគួរតែដោះស្រាយដោយសន្តិវិធី ។ ADR គួរតែត្រូវបានពង្រឹង។ |
| ៥. ជម្លោះដែលកើតឡើងនៅថ្នាក់មូលដ្ឋានមានការកើនឡើង។ | កំណើននៃជម្លោះទាំងនោះធ្វើឲ្យប៉ះពាល់ដល់វិមជ្ឈការ និងប្រជាធិបតេយ្យ។ | ធនធានគួរតែផ្ទេរទៅថ្នាក់មូលដ្ឋាន ពីព្រោះវិវាទក្នុងមូលដ្ឋានគួរតែដោះស្រាយនៅក្នុងមូលដ្ឋាន។ |

*ប្រភព៖ វិថីទៅកាន់យុត្តិធម៌៖ ការទទួលបាននូវយុត្តិធម៌ដែលផ្តោតទៅលើអ្នកក្រ ស្ត្រី និងជនជាតិភាគតិច ក្រសួងយុត្តិធម៌ និងUNDP ប្រទេសកម្ពុជា។*

## ៣. ការវិវត្តន៍នៃក្រមច័ណ្ឌច្បាប់ក្នុងការឆ្លើយតបទៅនឹងកំណែទម្រង់ច្បាប់ និងយុត្តិធម៌សម្រាប់ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ

ច្បាប់ជាច្រើនត្រូវបានអនុម័ត ដើម្បីជំរុញឲ្យមានដំណើរការប្រើប្រាស់ប្រព័ន្ធវិធានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ ច្បាប់ទាំងនេះនឹងត្រូវធ្វើការពិភាក្សាខាងក្រោម។

ក្នុងឆ្នាំ២០០១ ច្បាប់ស្តីពីរដ្ឋបាលឃុំ-សង្កាត់ បានអនុម័ត ដោយផ្តល់តួនាទីទៅរដ្ឋបាលឃុំសម្រាប់លើកស្ទួយតួនាទីដោះស្រាយជម្លោះរវាងប្រជាពលរដ្ឋ។ [57]

[57] Sub-Degree on Decentralization of Roles, Functions, and Power to Commune Councils (2002), Article 61.

បន្ថែមលើច្បាប់ខាងលើ មាត្រា៤៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ បានបង្កើតនូវគណៈកម្មការដោះស្រាយវិវាទដីធ្លី[58] ដោយមានភារកិច្ចចម្បងដោះស្រាយនូវជម្លោះរបស់ប្រជាពលរដ្ឋទាក់ទងនឹងដីមិនទាន់ចុះបញ្ជី ដោយមិនចាំបាច់ប្រើប្រាស់ប្រព័ន្ធតុលាការ។ [59] ប្រសិនបើគណៈកម្មការនេះ មិនអាចរកនូវដំណោះស្រាយសម្រាប់ភាគីជម្លោះនេះអាចនឹងត្រូវបញ្ជូនទៅតុលាការដើម្បីដោះស្រាយ។

សម្រាប់វិវាទការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីការងារត្រូវបានបង្កើតឡើងដោយប្រកាសលេខ ០៩៩ នៅក្នុងខែមេសា ឆ្នាំ២០០៤។

ដើម្បីក្លាយទៅជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក កម្ពុជាក៏បានយល់ព្រមបង្កើតនូវច្បាប់ថ្មីជាច្រើនដោយការប្តេជ្ញាពង្រឹងបទដ្ឋាននៃបទបញ្ញត្តិសម្រាប់ពាណិជ្ជកម្ម និងការវិនិយោគ។ ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ត្រូវបានអនុម័តនៅក្នុងឆ្នាំ២០០៦ ដោយកំណត់នូវក្របខណ្ឌសម្រាប់ មជ្ឈត្តកម្មឯកជននៅក្នុងការដោះស្រាយជម្លោះពាណិជ្ជកម្មដោយអនុវត្តតាមបទដ្ឋានអន្តរជាតិ។ មុនការអនុម័តនូវច្បាប់ស្តីពីមជ្ឈត្តកម្មពាណិជ្ជកម្ម កម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាក្រុងញូវយ៉ក ស្តីពីការទទួលស្គាល់ និងអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស (New York Convention on the Recognition and Enforcement of Foreign Arbitral Awards) នៅក្នុងឆ្នាំ១៩៦០ ។[60] ស្ថិតនៅក្រោមអនុសញ្ញានេះ ប្រទេសកម្ពុជាមានកាតព្វកិច្ចអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេស ប៉ុន្តែ ហាក់មានភាពមិនច្បាស់លាស់ថាតើមានការអនុវត្តនូវសេចក្តីសម្រេចអាជ្ញាកណ្តាលបរទេសហើយឬនៅទេ។[61]នៅក្នុងឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចុះហត្ថលេខាទៅលើអនុសញ្ញាស្តីពីការដោះស្រាយវិវាទទាក់ទងនឹងការវិនិយោគ (Convention on the Settlement of Investment Disputes: ICSID) ប៉ុន្តែ សភាមិនទាន់ផ្តល់សច្ចាប័នទៅលើអនុសញ្ញានេះនៅឡើយទេ។[62]

ក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ ក៏បានអនុញ្ញាតឲ្យមានការសម្របសម្រួលនៅក្នុង និងនៅក្រៅតុលាការផងដែរទោះបីជាភាគីបានដាក់បណ្តឹងទៅតុលាការហើយក៏ដោយ។ មាត្រា៩៧ បានចែងថា តុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងនោះស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ។ មាត្រា២២០ បានកំណត់ថា

---

58 The structure and general procedures were established by Sub-decree No. 47 ANK.BK (May 31, 2002) 'On the Organization and Functioning of the Cadastral Commission'. Procedures were elaborated by Prakas No. 112 DNS/BrK (August 21, 2002)'On the Guidelines and Procedures of the Cadastral Commission'.

59 Inter-Ministries Prakas No. 02 BRKN. 03 in 2003 'On Determination of Duty of the Court and Cadastral Commission Related to Land Disputes'.

60 Kong, "Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform" p. 14.

61 *Ibid.*

62 *Ibid.*

ការផ្សះផ្សាអាចធ្វើនៅក្រៅតុលាការក៏បាន។ បរិបទផ្នែកច្បាប់ទាំងនេះ មានតួនាទីយ៉ាងសំខាន់នៅក្នុងការទទួលស្គាល់ពីសារៈសំខាន់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការនៅស្ទើរគ្រប់វិស័យ។

## III. ការគ្រប់គ្រងជម្លោះនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

### ១. ថ្នាក់ក្រោមជាតិ

#### ១.១ ថ្នាក់ឃុំ សង្កាត់

ដើម្បីផ្តល់នូវស្វ័យភាពមួយចំនួនធំ ដល់រដ្ឋបាលថ្នាក់ក្រោមក្នុងការតំណាងដល់ផលប្រយោជន៍ប្រជាពលរដ្ឋឲ្យកាន់តែច្រើន ច្បាប់ពីរត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០០១ គឺច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ និងច្បាប់ស្តីការបោះឆ្នោតឃុំសង្កាត់ដែលផ្តល់នូវក្របខ័ណ្ឌច្បាប់សម្រាប់វិសហមជ្ឈការ។ ការបោះឆ្នោតឃុំសង្កាត់បានប្រព្រឹត្តទៅនៅក្នុងឆ្នាំ២០០២ ២០០៧ និង២០១២។ ផ្អែកទៅលើរបាយការណ៍វាយតម្លៃរបស់UNDP[63] នៅក្នុងឆ្នាំ២០០៩ សង្កាត់មានប្រហែល១៧១ និងឃុំមានប្រហែល១៦២១[64] ហើយក្នុងនោះមានស្ត្រីប្រហែល១៧.៧៨ភាគរយនៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់សរុបនៅក្នុងឆ្នាំ២០១២។[65] ឃុំនីមួយៗទទួលសំណុំរឿងប្រមាណ២៥សំណុំរឿងក្នុងមួយឆ្នាំ ហេតុនេះសម្រាប់១៦២១ឃុំ សំណុំរឿងចុះបញ្ជីទាំងអស់មានប្រមាណ៤០៥២៥។[66] តួអង្គសំខាន់ពីរត្រូវបានបង្កើតឡើងក្នុងតួនាទីផ្តល់នូវការដោះស្រាយវិវាទដោយសន្ទានកម្ម និងផ្សះផ្សា ដែលតួអង្គទាំងពីរនោះគឺ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និងមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ។

#### ១.១.១. គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់គឺជាគណៈកម្មាធិការដែលបង្កើតឡើងដោយឃុំ-សង្កាត់ដើម្បីជួយឃុំ-សង្កាត់ក្នុងការផ្សះផ្សាវិវាទ។ សិទ្ធិនៅក្នុងការបង្កើតនេះ មានចែងនៅក្នុងមាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់២០០១ ដែលឃុំ-សង្កាត់អាចបង្កើតគណៈកម្មាធិការផ្តល់នូវប្រឹក្សា និងជួយកិច្ចការដែលចាំបាច់។ ដូចដែលបានបញ្ជាក់នៅក្នុងសៀវភៅណែនាំការអនុវត្តការងារសម្រាប់គណៈកម្មាធិការដោះ

---

[63] Popovic, Velibor, Melim-McLeod, Claudi, " The Asia Pacific Rights and Justice Initiative: Cambodia Country Assessment." (UNDP, 2009). Accessed from http://www.undp.org/content/dam/aplaws/publication/en/publications/democratic-governance/dgttf-/cambodia-country-assessment-the-asia-pacific-rights-and-justice-initiative/Cambodia_A2JCountryAssessment.pdf.

[64] Ninh, Kim and Henke, Roger, "Commune Council in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution" (The Asia Foundation, 2005), p. 15. Accessed from https://asiafoundation.org/resources/pdfs/CBCCSurvey.pdf.

[65] Ministry of Women's Affair, "Neary Ratanak IV: Five Years Strategic Plan For Gender Equality and Women's Empowerment 2014-2018", p. 12.

[66] YRIGOYEN FAJARDO, Kong, and Phan, *Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples*, p. 106.

ស្រាយទំនាស់ឃុំ-សង្កាត់ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងក្នុងនាមជាគម្រោងសាកល្បងនៅក្នុងឆ្នាំ ២០០៦។[67] តួនាទីរបស់គណៈកម្មាធិការមានដូចតទៅ៖

- គ្រប់គ្រង និងកាត់បន្ថយជម្លោះមូលដ្ឋាន
- សន្ទានកម្ម និងផ្សះផ្សាជម្លោះ ប្រសិនបើភាគីយល់ព្រម
- ចែកចាយព័ត៌មានផ្នែកច្បាប់ទៅមូលដ្ឋាន
- ជួយក្រុមប្រឹក្សាឃុំសង្កាត់ក្នុងការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ[68]

គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់រួមមាន សមាជិកក្រុមប្រឹក្សាឃុំសង្កាត់មួយរូបជាប្រធាន សមាជិកក្រុមប្រឹក្សាជានារីមួយរូបជាអនុប្រធាន ប្រធានប៉ុស្តិ៍នគរបាលមួយរូប និងប្រជាជនដែលមានការគោរពរាប់អានបួនរូបជាសមាជិក។[69] សំណុំរឿងភាគច្រើន ដែលទទួលបាន មានដូចជា៖

- ទំនាស់ដីធ្លី
- បំណុល និងកិច្ចសន្យា
- លែងលះ
- ជេរប្រមាថ
- វិវាទមុនរៀបអាពាហ៍ពិពាហ៍
- ទំនាស់ទាក់ទងនឹងទ្រព្យសម្បត្តិ
- អំពើហឹង្សាក្នុងគ្រួសារ
- ការបង្ករបួសស្នាម
- ករណីផ្សេងៗទៀត[70]

មានករណីមួយចំនួនដែលគណៈកម្មាធិការនេះមិនគួរធ្វើការផ្សះផ្សានោះទេ ជាក់ស្តែងដូចជារឿង ព្រហ្មទណ្ឌ ឧទាហរណ៍ដូចជា ករណីរំលោភ ឬសម្លាប់ រឿងដីធ្លីដែលមានបណ្ណកម្មសិទ្ធិ(ប្លង់រឹង) វិវាទដែលភាគីមិនយល់ព្រមទទួលយកការផ្សះផ្សា និងវិវាទដែលសន្ទានការី ឬអ្នកផ្សះផ្សាមានទំនាស់ផលប្រយោជន៍ជាមួយនឹងភាគីវិវាទ។ [71]

យោងទៅតាមសៀវភៅណែនាំអនុវត្តការងារសម្រាប់គណៈកម្មាធិការ គណៈកម្មាធិការគួរតែរក្សានូវភាពមានវិជ្ជាជីវៈឲ្យដូចទៅនឹងតុលាការ ដែលតួនាទីនេះរួមមានការរក្សានូវការសម្ងាត់ ទំនុកចិត្ត សមភាព យុត្តិធម៌ និង

[67] *UNDP-Cambodia Operation manual for commune dispute resolution committee (CDRC), (UNDP-Cambodia 2010),* p. 1, http://www.un.org.kh/undp/media/files/OperationsmanualforCommuneDisputeResolutionCommittee_Eng.pdf.
[68] *Ibid.*
[69] *Ibid.*
[70] Ibid., p. 14.
[71] *Ibid.*, p.17.

ការជៀសវាងទំនាស់ផលប្រយោជន៍។[72] គិតត្រឹមចុងឆ្នាំ២០១៣ គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ មានប្រហែល៥៦គណៈកម្មាធិការ ដោយក្នុងចំណោមសមាជិកចំនួន ៣៩២នាក់ មានសមាជិកស្ត្រីចំនួន ១១៦ នាក់។[73]

រូបភាពទី៤ និងទី៥ ផ្ដល់នូវតួលេខអំពីចំនួន និងប្រភេទវិវាទដែលទទួលបានដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ចាប់តាំងពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១៣។

**រូបភាពទី៤៖ ស្ថិតិនៃករណីបានទទួលដោយគណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់**




*ប្រភព: ក្រសួងយុត្តិធម៌* របាយការណ៍ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លេខ ០២ សតយ/១៤ ចុះថ្ងៃទី ១៤ខែមករា ឆ្នាំ ២០១៤។

**រូបភាពទី៥៖ ស្ថិតិនៃប្រភេទជម្លោះ**




*ប្រភព: ក្រសួងយុត្តិធម៌ របាយការណ៍ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លេខ ០២ សតយ / ១៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ។*

---

[72] *Ibid.*, p. 26.

[73] Ministry of Justice, Report to the Minister of the Ministry of Justice No. 02 STY/14 dated January 14, 2014.

យោងទៅតាមរបាយការណ៍វាយតម្លៃឆ្នាំ២០០៩ និង ឆ្នាំ២០១០របស់ UNDP គណៈកម្មាធិការនេះទទួលបាននូវទំនុកចិត្តពីអ្នកប្រើប្រាស់សេវា ដោយសារតែភាគីទាំងពីរមានសិទ្ធិជ្រើសរើសសន្ទានការី (សន្ទានការីពីររូបជ្រើសរើសដោយភាគីទាំងពីរ និងសន្ទានការីទីបី ជ្រើសរើសដោយគណៈកម្មាធិការ)។[74] អ្នកប្រើប្រាស់សេវា ក៏បញ្ចេញនូវទស្សនៈរបស់គេផ្ទាល់ថា គណៈកម្មាធិការនេះមានតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឲ្យមានការទទួលបាននូវយុត្តិធម៌ ហើយសេវានេះគួរតែត្រូវបានបន្ត។[75] ចំណុចដែលជាការប្រឈមសំខាន់របស់គណៈកម្មាធិការនោះគឺ ការមិនមានសន្ទានការី សម្រាប់ដោះស្រាយសំណុំរឿងនៅពេលណាដែលឈ្មោះរបស់សន្ទានការីនោះត្រូវបានជ្រើសរើសដោយភាគីពីក្នុងបញ្ជី គឺភាគច្រើនសន្ទានការីនោះមិនទំនេរដើម្បីទទួល សំណុំរឿងនោះទេ ហេតុនេះភាគីច្រើនតែឃើញមានតែមនុស្សដដែលៗ មកផ្សះផ្សាសំណុំរឿង (ដូចជាប្រធាន អនុប្រធានរបស់គណៈកម្មការ និងសមាជិកទីបីដែលទំនេរ)។[76] មូលហេតុដែលមិនមានសន្ទានការី គឺបណ្តាលមកពីមិនមានមូលនិធិគ្រប់គ្រាន់ (សម្រាប់ការចំណាយលើការធ្វើដំណើររបស់សន្ទានការី) និងដោយសារសន្ទានការីទាំងនោះមានមុខរបរផ្សេងៗទៀត។[77] ទោះបីជាយ៉ាងណាក៏ដោយ របាយការណ៍ចុងក្រោយរបស់ UNDP បញ្ជាក់ថា គណៈកម្មាធិការនេះមានភាពជោគជ័យក្នុងការងារ។[78]

### ១.១.២ មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ

មណ្ឌលសេវាកម្មយុត្តិធម៌ក្រុង-ស្រុក-ខណ្ឌ ត្រូវបានបង្កើតឡើងដោយប្រកាសអន្តរក្រសួង លេខ៨៥ប្រក កយ មផ/០៦ របស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។ មណ្ឌលសេវាកម្មនេះមានតួនាទីដូចតទៅៈ[79]

- ផ្តល់នូវការបណ្តុះបណ្តាល និង/ឬ ការប្រឹក្សាបច្ចេកទេសទៅក្រុមប្រឹក្សា ឃុំ-សង្កាត់ ទៅលើការផ្សះផ្សា រួមទាំងបញ្ហាផ្នែកច្បាប់មួយចំនួន
- ធ្វើការប៉ាន់ប្រមាណអំពីតម្រូវការព័ត៌មានផ្នែកច្បាប់នៅថ្នាក់ស្រុក និងឃុំ
- ផ្សព្វផ្សាយព័ត៌មានផ្នែកច្បាប់ចាំបាច់ដល់សាធារណៈជននៅមូលដ្ឋាន
- ធ្វើការផ្សះផ្សា និងធ្វើសន្ទានកម្មវិវាទក្នុងករណីមានការស្នើសុំពីភាគី
- ផ្តល់សេវាពិគ្រោះយោបល់ និងចង្អុលផ្លូវ ដល់ភាគីវិវាទដែលមិនទាន់បានដោះស្រាយនៅថ្នាក់មូលដ្ឋាននៅឡើយ ។

ចាប់ផ្តើមដំបូងនៅក្នុងឆ្នាំ២០០៦ មណ្ឌលសេវាកម្មនេះ មានចំនួន៤តែប៉ុណ្ណោះ ដែលនេះ គ្រាន់តែជាគម្រោងសាកល្បង។ ចាប់ពីឆ្នាំ២០១៣ ចំនួននេះកើនឡើងរហូតដល់៣១ស្រុក ដោយក្នុងនោះមានស្ត្រីចំនួន២៩រូប នៅ

[74] Popovic, McLeod, " The Asia Pacific Rights and Justice Initiative: Cambodia Country Assessment." (UNDP, 2009), p. 13; and McGrew, Laura, and Doung, Virorth, "Access to Justice Project in Cambodia: Final Evaluation Report. (UNDP-2010), p. vi.
[75] McGrew and Doung, "Access to Justice Project in Cambodia: Final Evaluation Report."
[76] *Ibid*.
[77] *Ibid*.
[78] *Ibid*.
[79] Inter-ministerial Prakas No. 85Rbk/MOJ/MOI/06, Article 3.

ក្នុងចំណោមសមាជិក៩៣រូប។[80] មន្ត្រីរបស់មណ្ឌលសេវាកម្មត្រូវតែអនុវត្តនូវក្រម សីលធម៌ផ្នែកវិជ្ជាជីវៈដែលចងក្រងដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ហើយក្រសួងនេះមាន តួនាទីធានាថាមន្ត្រីទាំងអស់យល់ដឹងបានល្អនូវក្រមសីលធម៌នេះ។[81] មន្ត្រីទាំងអស់ត្រូវតែមានភាពស្មោះត្រង់និងបរិសុទ្ធ គណនេយ្យភាព ភាពរក្សានូវការសម្ងាត់ តម្លាភាព មិនមានការរើសអើង និងមិនមានទំនាស់ផលប្រយោជន៍។[82] មណ្ឌលរបស់ស្រុកនីមួយៗត្រូវដឹកនាំដោយប្រធានមួយរូបតែងតាំងដោយក្រសួងយុត្តិធម៌ និងលេខាម្នាក់ ប្រសិនបើចាំបាច់។[83] ភាគច្រើននៃប្រធានដែលតែងតាំងច្រើនតែជាអតីតក្រឡាបញ្ជី ដែលទទួលជំនួយពីបុគ្គលិកក្រសួងយុត្តិធម៌ដែលមានមូលដ្ឋាននៅភ្នំពេញ។[84]

រូបភាពទី៦ និងទី៧ ផ្តល់នូវតួលេខអំពីចំនួន និងប្រភេទនៃសំណុំរឿងដែលទទួលបានដោយមណ្ឌលសេវាកម្មយុត្តិធម៌ ក្រុង-ស្រុក-ខណ្ឌ ចាប់តាំងពីបង្កើតរហូតដល់ឆ្នាំ២០១៣។ [85]
ការងាររបស់មណ្ឌលសេវាកម្មនេះត្រូវបានរាយការណ៍ដោយក្រសួងយុត្តិធម៌ និងUNDP មកថា ទទួលបានជោគជ័យតែមួយផ្នែកប៉ុណ្ណោះ ដោយសារមាន អវត្តមានរបស់ប្រធានមណ្ឌលច្រើន សំណុំរឿងទទួលបានតិច កង្វះខាតការផ្សព្វផ្សាយព័ត៌មាន និងកង្វះការគ្រប់គ្រង និងកង្វះការគាំទ្រទៅដល់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំសង្កាត់។[86] មូលហេតុទាំងអស់នេះគឺកើតឡើងដោយសារតែមិនមានថវិកាគ្រប់គ្រាន់សម្រាប់កិច្ចការរដ្ឋបាល។[87] របាយការណ៍របស់ UNDP ពីបញ្ហាប្រឈមទាំងនេះ មានភាពស្របគ្នាទៅនឹងរបាយការណ៍របស់ក្រសួងយុត្តិធម៌។[88] ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលបានបន្ថែមថា បញ្ហាប្រឈមសំខាន់របស់គណៈកម្មាធិការ និងមណ្ឌលសេវាកម្មមួយទៀតនោះគឺ សេចក្តីព្រាងអនុក្រឹត្យទៅលើការពង្រឹង និងពង្រីកប្រព័ន្ធដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការមានការយឺតយ៉ាវដែលនាំទៅដល់ការមិនមានថវិការគ្រប់គ្រាន់។[89]

**រូបភាពទី៦៖ ស្ថិតិនៃសំណុំរឿងដែលបានទទួលដោយមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ**




*ប្រភព: ក្រសួងយុត្តិធម៌ របាយការណ៍ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លេខ ០២ សតយ/១៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤។*

[80] Ministry of Justice, Report to the Minister of the Ministry of Justice No. 02 STY/14 dated January 14, 2014.

[81] *UNDP-Cambodia Operation manual for the maison de la justice (UNDP-Cambodia, 2010)*, p. 1. Accessed from http://www.un.org.kh/undp/media/files/OperationsmanualforCentreofJusticeService_Eng.pdf.

[82] *Ibid.*, pp. 2-4.

[83] Inter-ministerial Prakas No. 85Rbk/MOJ/MOI/06. Articles 2 and 6.

[84] McGrew and Doung, "Access to Justice Project in Cambodia: Final Evaluation Report", p. 17.

[85] Ministry of Justice, Report to the Minister of the Ministry of Justice No. 02 STY/14 dated January 14, 2014.

[86] *Ibid.*

[87] *Ibid.*

[88] *Ibid.*

[89] *Ibid.*

រូបភាពទី៧៖ ស្ថិតិនៃប្រភេទជម្លោះដែលបានទទួលដោយមណ្ឌលសេវាកម្មយុត្តិធម៌ក្រុង ស្រុក ខណ្ឌ




*ប្រភព:ក្រសួងយុត្តិធម៌ របាយការណ៍ទៅកាន់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លេខ ០២ សតយ / ១៤ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១៤ ។*

## ១.២ គណៈកម្មការសុរិយោដី

គណៈកម្មការសុរិយោដីបានបង្កើតឡើងដោយមាត្រា៤៧ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ហើយអនុក្រឹត្យលេខ ៤៧ អនក្រ បក (ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២) កំណត់ពីរចនាសម្ពន្ធ័ និងនីតិវិធីទូទៅនៃគណៈកម្មការនេះ។

គណៈកម្មការសុរិយោដីមានអាណត្តិដោះស្រាយវិវាទដីធ្លីដែលមិនបានចុះបញ្ជី និងស្ថិតនៅក្រៅតំបន់វិនិច្ឆ័យ និងនៅក្នុងតំបន់វិនិច្ឆ័យ[90] ដែលភាគីមិនបានព្រមព្រៀងគ្នា ព្រមទាំងទំនាស់ដីធ្លីនៅក្នុងតំបន់វិនិច្ឆ័យដែលថ្នាក់រដ្ឋបាលរបស់គណៈកម្មការនេះមិនអាចផ្សះផ្សាបាន។[91] គណៈកម្មការសុរិយោដីមានបីថ្នាក់គឺថ្នាក់ស្រុកខណ្ឌ ថ្នាក់ខេត្តក្រុង និងថ្នាក់ជាតិ។[92] ប៉ុន្តែ ថ្នាក់ស្រុកខណ្ឌ និងថ្នាក់ខេត្តក្រុង ត្រូវបានប្តូរមកជាថ្នាក់ក្រុង ស្រុកខណ្ឌ និងថ្នាក់រាជធានីខេត្ត។[93] ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌បានអនុម័តនូវប្រកាសអន្តរក្រសួងលេខ ០២ ប្រករ ០៣នៅក្នុងឆ្នាំ២០០៣ ស្តីពីការកំណត់ភារកិច្ចរបស់

---

[90] តំបន់វិនិច្ឆ័យគឺ ជាទីតាំងដែលត្រូវបានជ្រើសរើសដោយគណៈកម្មការ ក្នុងការផ្តល់នូវការចុះបញ្ជី និងផ្តល់នូវបណ្ណកម្មសិទ្ធិ តាមរយៈការចុះបញ្ជីដីជាប្រព័ន្ធ និងដាច់ដោយដុំ។

[91] Sub Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002. Article 3.

[92] Sub Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002. Article 4.

[93] Royal Kram on Law on Constitutional Amendment on Article 145 and 146 NS.RKM/0208/008/February 15, 2008 and Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans May 22, 2008.

តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លី។ ប្រកាសនេះ បែងចែកសមត្ថកិច្ចរវាងតុលាការ និងគណៈកម្មការ ដោយកំណត់ថា គណៈកម្មការនេះត្រូវធ្វើការដោះស្រាយនូវរាល់ជម្លោះដីដែលមិនបានចុះបញ្ជី លើកលែងតែដីដែលទាក់ទងនឹងកេរ្តិ៍មរតក (រវាងអ្នកទទួលមរតក) ឬកិច្ចសន្យា (រវាងភាគីនៃកិច្ចសន្យា) ដែលជម្លោះទាំងនេះគឺជាសមត្ថកិច្ចរបស់តុលាការ។

**រូបភាពទី៨៖ ស្ថិតិនៃការវិវាទដីធ្លីដែលត្រូវបានដោះស្រាយដោយគណៈកម្មការសុរិយោដី ២០០៣-២០០៩**

| ការវិវាទដីធ្លីដែលត្រូវបានដោះស្រាយដោយគណៈកម្មការសុរិយោដី ២០០៣-២០០៩ | | | | | | |
|---|---|---|---|---|---|---|
| ឆ្នាំ | ចំនួនករណី | ករណីដែលឈានដល់ការដោះស្រាយ | ករណីដែលបដិសេធយកមកដោះស្រាយ | ករណីដែលបញ្ជូនទៅតុលាការ | ករណីដែលមិនទាន់សម្រេច | ករណីដែលដកចេញវិញដោយភាគី |
| **២០០៣** | ១២៤៥ | ២៧១ | ៨២ | ២ | ៨៩០ | 0 |
| **២០០៤** | ២០៧៩ | ៥៥៣ | ១២៥ | 0 | ១៣១៩ | 0 |
| **២០០៥** | ៣៨៥៦ | ៤០២ | ៣៨២ | 0 | ១៨៦៣ | ៤៩ |
| **២០០៦** | ៤២៥៤ | ១២៤៦ | ៨៧១ | ៦១ | ២០៥៦ | ៧៩ |
| **២០០៧** | ៤៦៨៩ | ១៤៣៩ | ១០៦៦ | ៨០ | ២០៦០ | ១២៤ |
| **២០០៨** | ៥០៣៨ | ១៦៥៣ | ១២១៣ | ៨៤ | ១៩៥២ | ២២០ |
| **២០០៩** | ៥១៩៣ | ១៨១០ | ១៣៦៩ | ៩៧ | ១៧៤២ | ២៧២ |

*ប្រភព: លេខាធិការដ្ឋាន គណៈកម្មការសុរិយោដី របាយការណ៍ជាតិប្រចាំឆ្នាំ ពីឆ្នាំ ២០០៣ ដល់ឆមាសទី ១ ឆ្នាំ២០០៩ (១៦ កក្កដា ២០០៩) ដែលមានចែងនៅក្នុង ទ្រី ហ៊ាង វិវាទដីធ្លីនៅកម្ពុជា ឆ្នាំ២០០១ ដល់២០០៩ (Royal Academic of Cambodia-2012)*

ចំនួនតួលេខថ្មីៗ នៃសំណុំរឿងដែលគណៈកម្មការទទួលបានពីឆ្នាំ២០០៣ ដល់ខែមេសា ឆ្នាំ២០១៤ គឺមានសរុបប្រមាណ ៦.២២៤សំណុំរឿង និង ៥.៣៧០សំណុំរឿងត្រូវបានដោះស្រាយ (ដោយក្នុងនោះ ២.៧២៤បានសះជា ២,០១១ច្រានចោល និង៦១៧ត្រូវបានដកពាក្យបណ្ដឹង)។ សំណុំរឿងចំនួន៨៥៤គឺនៅមិនទាន់ដំណើរការដោះស្រាយទេ។[94] យោងទៅលើចំនួនតួលេខនៅរូបភាពទី៨ខាងលើ និងចំនួនតួលេខថ្មីៗ ចំនួនសំណុំរឿងមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ ទន្ទឹមនឹងនោះ ចំនួនសំណុំរឿងដែលច្រានចោលក៏មានការកើនឡើងដូចគ្នា។ គណៈកម្មការមានសិទ្ធិច្រានចោលនូវបណ្ដឹងដែលធ្វើឡើងដោយមិនត្រឹមត្រូវ គ្មានមូលដ្ឋាន ឬធ្វើឡើងដើម្បីយាយី ឬបំភ័យភាគីម្ខាងទៀត ទោះបីជាការច្រានចោលសំណុំរឿងនោះមិនគួរធ្វើ ប្រសិនបើមិនមានភាពចំបាច់ដើម្បីកុំឲ្យមានភាពអយុត្តិធម៌កើតឡើង។[95] យោងទៅតាមការស្រាវជ្រាវរបស់ GTZ-

[94] The NGO Forum on Cambodia *Statistical Analysis of Land Disputes in Cambodia, 2013* ( NGOForum, 2014), p. 4.
[95] Prakas No 112 DNS/Brk on The Guidelines and Procedures of the Cadastral Commission. Article 19.

Cambodia និងធនាគារពិភពលោក ការសម្រេចចិត្តនៅក្នុងការច្រានចោលនូវសំណុំរឿងគឺធ្វើឡើងដំណាក់កាលផ្សេងៗ និងតាមរបៀបមួយមិនទៀងទាត់ទេ។ [96]

ភាពជោគជ័យរបស់គណៈកម្មការនេះ ដូចដែលត្រូវបានរាយការណ៍ដោយ GTZ គឺការរៀបចំ និងការវិវត្តន៍នៃនីតិវិធីការដោះស្រាយវិវាទ ប៉ុន្តែ ការអនុវត្តជាក់ស្តែងនៃនីតិវិធីនោះ ក៏មិនត្រូវបានអនុវត្តដោយត្រឹមត្រូវនោះទេ។[97] បញ្ហាទាំងនេះ ភាគច្រើន ទាក់ទងនឹង ១)របៀបដែលភាគីវិវាទជ្រើសរើសអ្នកផ្សះផ្សា ២)របៀបដែលភាគីទទួលបានព័ត៌មានពីដំណើរការ និងច្បាប់ដែលទាក់ទងនឹងវិវាទ និង៣) មូលដ្ឋាននៃការសម្រេចចិត្តនៅក្នុងការច្រានចោលបណ្តឹងរបស់គណៈកម្មការ និង៤) របៀបចុះបញ្ជីដីធ្លីនៅពេលដែលភាគីមានការឯកភាពគ្នា។[98] ជាឧទាហរណ៍ ធម្មតានៅថ្នាក់ស្រុកខណ្ឌ ប្រធានគណៈកម្មការណែនាំសមាសភាពរបស់អ្នកផ្សះផ្សាដល់ភាគីវិវាទ ដោយក្នុងនោះមានទាំងខ្លួនគាត់ផងដែរ ជាជាងអនុញ្ញាតឲ្យភាគីជ្រើសរើសដោយខ្លួនឯង។[99] នេះគឺជាហេតុផលដែលធ្វើឲ្យភាគីពេញចិត្តទៅលើការដោះស្រាយរបស់គណៈកម្មការតែ៥០ភាគរយប៉ុណ្ណោះ។[100] ខាងក្រោមនេះនឹងបង្ហាញសង្ខេបពីគណៈកម្មការសុរិយោដីទាំងបីថ្នាក់។

### ១.២.១. គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ

គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌនេះដឹកនាំដោយអភិបាលស្រុកខណ្ឌ[101] ដែលអាចអញ្ជើញអ្នកតំណាង ស្រុក ខណ្ឌ ឃុំ-សង្កាត់ និងអាជ្ញាធរភូមិ និងចាស់ទុំនៅមូលដ្ឋានឲ្យចូលរួមធ្វើជាសមាជិកចំពោះកិច្ច (Ad Hoc members)។ គណៈកម្មការនេះមានតួនាទីផ្សះផ្សាជម្លោះដែលកើតឡើងក្រៅតំបន់វិនិច្ឆ័យ។ ការផ្សះផ្សានេះ ត្រូវធ្វើដោយយោងទៅលើទំនៀមទម្លាប់ ផ្សារភ្ជាប់នឹងបច្ចេកទេស។[102] ប្រសិនបើការផ្សះផ្សាបរាជ័យនៅគណៈកម្មការថ្នាក់ក្រុង ស្រុក ខណ្ឌ វិវាទនេះដាក់ជូនដល់គណៈកម្មការរាជធានី ខេត្ត ដោយសំអាងទៅលើមូលហេតុដូចខាងក្រោម៖[103]

- ជនម្នាក់ទាមទារដីច្រើនក្បាលដែលមានម្ចាស់ដីតូចៗកំពុងទាមទារដែរ។
- ភាគីម្ខាងនៃវិវាទមានឋានៈខ្ពស់
- ករណីវិវាទមានទំនាស់ផលប្រយោជន៍នឹងប្រធានគណៈកម្មការថ្នាក់ក្រុង ស្រុក ខណ្ឌ និង

---

96 *GTZ-Cambodia and The world BanK, Toward Institutional Justice? A review of Cambodia's Cadastral Commission in Relation to Land Dispute Resolution (GTZ-Cambodia and The world Bank, 2006)*, p. XV.

97 *Ibid.*, p. XII.

98 *Ibid.*

99 *Ibid.*

100 *Ibid.*

101 *New Article 5 sub-Degree on the Amendment on Article 5 and Article 28 of Sub Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002 (No.34 ANK.BK/April 20, 2006).*

102 *Sub Decree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002. Article 6.*

103 *Sub Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002. Article 10.*

- វិវាទពាក់ពន្ធ័នឹងដីសាធារណៈរបស់រដ្ឋ។

គណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ មានសិទ្ធិច្រានចោលនូវបណ្តឹងដែលធ្វើឡើងដោយមិនត្រឹមត្រូវ គ្មានមូលដ្ឋាន ឬធ្វើឡើងដើម្បីយាយី ឬបំភ័យភាគីម្ខាងទៀត។ ទោះបីជាយ៉ាងណាក៏ដោយ ការច្រានចោលនេះមិនគួរធ្វើទេ ប្រសិនបើមិនមានភាពចំបាច់ ។[104] រូបភាពទី៩ ខាងក្រោមបង្ហាញពីដំណើរការ ការងារក៏ដូចជារយៈពេលសម្រាប់ដោះស្រាយវិវាទនៅថ្នាក់ ក្រុង ស្រុក ខណ្ឌរបស់គណៈកម្មការសុរិយោដី។ ជាទូទៅ ជម្លោះដីធ្លីដែលនាំមកដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ ជាវិវាទដែលមិនសះជា នៅថ្នាក់ភូមិឃុំ។[105]

**រូបភាពទី៩៖ ដំណាក់កាលទាំង៥ដែលគណៈកម្មការសុរិយោដីថ្នាក់ក្រុង ស្រុក ខណ្ឌ**



*ប្រភព: ដំណើរឆ្ពោះទៅកាន់ស្ថាប័នយុត្តិធម៌? ការសិក្សាទៅលើគណៈកម្មការសុរិយោដីទាក់ទងនឹងការដោះស្រាយវិវាទដីធ្លីនៅកម្ពុជា (GTZ-Cambodia and The world Bank, 2006)*

## ១.២.២. គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត

សមាសភាពគណៈកម្មការសុរិយោដីថ្នាក់រាជធានី-ខេត្តរួមមាន អភិបាល ឬអភិបាលរងរាជធានី ខេត្ត ជាប្រធាន ហើយប្រធានមន្ទីរសុរិយាដីរាជធានី ខេត្តគឺជាសមាជិក។[106] គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្តមានតួនាទីផ្សះផ្សាវិវាទដែលនៅក្រៅសមត្ថកិច្ចរបស់គណៈកម្មការថ្នាក់ក្រុងស្រុក ខណ្ឌ និងវិវាទដែលគណៈកម្មការនេះមិនអាចផ្សះផ្សាបាន។[107] ពីមុន គណៈកម្មការសុរិយោដីរាជធានីខេត្ត មិនមានអំណាចធ្វើការសម្រេចចិត្តទេ។ ប៉ុន្តែ នៅដើមឆ្នាំ២០១០ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់បានធ្វើប្រតិភូកម្មអំណាចឲ្យទៅប្រធាន

---

[104] Prakas No 112 DNS/Brk on The Guidelines and Procedures of the Cadastral Commission. Article 19.

[105] *GTZ-Cambodia and The world BanK Toward Institutional Justice? A review of Cambodia's Cadastral Commission in Relation to Land Dispute Resolution, pp. 118-119.*

[106] Sub Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002. Article 12.

[107] *Ibid*., Article 13.

គណៈកម្មកាសុរិយោដីរាជធានីខេត្ត ធ្វើការសម្រេចចិត្តបាន។[108] ភាគីវិវាទដែលមិនយល់ព្រមជាមួយការសម្រេចចិត្តរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត អាចធ្វើការប្តឹងតវ៉ាទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិបានក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលនូវការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត ប៉ុន្តែប្រសិនបើមិនធ្វើការប្តឹងតវ៉ានៅក្នុងរយៈពេលនេះទេ សេចក្តីសម្រេចត្រូវចាត់ទុកថាបានការ។[109]

# ២. ថ្នាក់ជាតិ

## ២.១. គណៈកម្មការសុរិយោដីថ្នាក់ជាតិ

គណៈកម្មការសុរិយោដីថ្នាក់ជាតិគឺជាគណៈកម្មការដែលមានឋានានុក្រមខ្ពស់បំផុតនៅក្នុងប្រព័ន្ធរដ្ឋបាលរបស់គណៈកម្មការសុរិយោដី។ គណៈកម្មការនេះរួមមានរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងរដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក។[110] គណៈកម្មការនេះមានសមត្ថកិច្ចធ្វើការសម្រេចចិត្តនៅលើសំណុំរឿងទាំងអស់ដែលថ្នាក់ក្រោមដោះស្រាយមិនបាន និងមានសមត្ថភាពពេញលេញនៅក្នុងការសម្រេចថាអ្នកណាគឺជាកម្មសិទ្ធករនៅលើដី(អ្នកមានកម្មសិទ្ធពេញច្បាប់)។[111] នៅពេលដែលមានការស្នើសុំពីភាគី គណៈកម្មការនេះអាចបើកសវនាការដើម្បីស្តាប់គូភាគី។[112] ប្រសិនបើគណៈកម្មការថ្នាក់ជាតិនេះធ្វើការសម្រេចចិត្តជាលាយលក្ខអក្សរ ហើយភាគីមិនពេញចិត្ត ភាគីទាំងនេះអាចស្នើសុំទៅតុលាការដើម្បីពិនិត្យឡើងវិញក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលនូវសេចក្តីសម្រេចនោះ។[113]តុលាការអាចសម្រេចបញ្ជូនរឿងមកគណៈកម្មការសុរិយោដីដើម្បីពិនិត្យឡើងវិញ ប្រសិនបើតុលាការរកឃើញថាមិនមានការគោរពនីតិវិធីត្រឹមត្រូវ មានទំនាស់ផលប្រយោជន៍ និងសំណុំរឿងស្ថិតនៅក្រៅសមត្ថកិច្ចរបស់ខ្លួន។[114]

នៅក្នុងឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានបង្កើតនូវស្ថាប័នមួយទៀតហៅថា អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី។[115] ប្រធានអាជ្ញាធរនេះតំណាងឲ្យនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងដែនដីនគររូបនីយកម្ម និងសំណង់ ជាអនុប្រធាន និងមានការចូលរួមពីតំណាងអង្គការក្រៅរដ្ឋាភិបាលពាក់ពន្ធ័សំខាន់ៗផងដែរ។[116] អាជ្ញាធរនេះមានភារកិច្ចដោះស្រាយនូវទំនាស់ដីធ្លីទាំងអស់ដែលស្ថិតនៅក្រៅសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។[117] ចំណុចនេះ ហាក់មានន័យថា សមត្ថកិច្ចរបស់អាជ្ញាធរនេះគឺជាន់គ្នានឹងសមត្ថកិច្ចរបស់តុលាការទាក់ទងនឹងទំនាស់

---

108 Prakas on Power Delegation to Governor and Capital and Provincial Councilor 032 BRK.DNS/KSC dated January 21, 2010.
109 Circulation on the Procedure to implement the decision of Capital and Provincial Cadastral Commission dated January 21 2010.
110 Sub Descree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002, Article 17.
111 *Ibid.*, Articles 19 and 20.
112 *Ibid.,* Article 21.
113 *Ibid.,* Article 23.
114 *Ibid*.
115 Royal Decree on establishment of establishment of National Authority to Settle Land Dispute, NS/RKT/0206/097 February 26, 2006.
116 *Ibid.,* Article1.
117 *Ibid.,* Article 3.

ដីធ្លីដែលបានចុះបញ្ជី ហើយដែលនៅក្រៅសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ។[118] ចាប់តាំងពីអាជ្ញាធរបានបង្កើតមករហូតដល់ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០០៩[119] អាជ្ញាធរនេះទទួលបានសំណុំរឿងប្រហែល១១៩២ ហើយមានតែសំណុំរឿងចំនួន ៣៨ ប៉ុណ្ណោះដែលបានដោះស្រាយ។ (សូមមើលរូបភាពទី១០ ខាងក្រោម)

**រូបភាពទី១០៖ ចំនួនករណីដាក់ទៅកាន់អាជ្ញាធរជាតិដើម្បីដោះស្រាយវិវាទដីធ្លី ២០០៦-២០០៩**




*ប្រភព: របាយការណ៍របស់អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី លេខ ០០៣ ក្របក រភដ ២០០៩ ដែលមានដកស្រង់នៅក្នុង ការស្រាវជ្រាវរបស់ ទ្រី ហ៊ាង មានចំណងជើងថា វិវាទដីធ្លីនៅកម្ពុជា ឆ្នាំ២០០១ ដល់២០០៩ (Royal Academic of Cambodia)-*

## IV. បទពិសោធន៍ពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល

ទោះបីជាក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវបានចែងនៅក្នុងច្បាប់ស្ដីការងារតាំងពីឆ្នាំ១៩៩៧ក៏ដោយ[120] ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះទើបនឹងបង្កើតឡើងនៅក្នុងឆ្នាំ២០០៤ តាមប្រកាសលេខ០៩៩។[121] ក្រុមប្រឹក្សានេះ មានសមត្ថកិច្ចពិនិត្យនូវវិវាទការងាររួម (collective labor disputes)[122] នៅពេលដែលនីតិវិធីរបស់ក្រុមប្រឹក្សានេះបានចែងនៅក្នុងអនុសញ្ញារួម និងសមត្ថកិច្ចរបស់ក្រុមប្រឹក្សានេះដែលមានចែងនៅក្នុងមាត្រា៣០៩ ដល់៣១៧ នៃច្បាប់ស្ដីពីការងារ។[123] នៅពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទទួលវិវាទ សមាជិកបីរូបនៃក្រុមអាជ្ញាក

[118] Inter-Ministries Prakas No. 02 BRKN.03 in 2003 ‘On Determination of Duty of the Court and Cadastral Commission Related to Land Disputes’.
[119] Horng, Try, *“Land Conflict in Cambodia2001-2009”,* p. 111.
[120] Cambodian Labour Law, Articles 309-317.
[121] Prakas 099 , Arbitration Council, April 21, 2004.
[122] Collective dispute is the dispute involves one or more employers and a number of employees, as a group or trade union (Article 302 of the Labour Law).
[123] Cambodian Labour Law, Article 309.

ណ្តាលនឹងត្រូវបានជ្រើសរើសដើម្បីដោះស្រាយវិវាទនោះ។ ភាគីនីមួយៗនៃវិវាទមានសិទ្ធិជ្រើសរើសសមាជិកម្នាក់១រូប។ បន្ទាប់មកសមាជិកទាំងពីរដែលបានជ្រើសរើសរួច ត្រូវជ្រើសរើសនូវសមាជិកទីបីចេញពីបញ្ជីឈ្មោះមជ្ឈត្តកររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។[124] ក្រុមប្រឹក្សានេះមានតួនាទីស្របច្បាប់នៅក្នុងការបកស្រាយ និងអនុវត្តនូវច្បាប់ និងបទបញ្ជា ឬអនុសញ្ញារួម។[125] បន្ថែមពីលើនេះទៀត ក្រុមប្រឹក្សាមានអំណាចនៅក្នុងការស៊ើបអង្កេតពីស្ថានភាពសេដ្ឋកិច្ចរបស់រោងចក្រសហគ្រាស និងមានអំណាចស្នើសុំឲ្យភាគីផ្តល់ភស្តុតាង និងឯកសារពាក់ពន្ធ័ទាំងអស់។[126] ប៉ុន្តែ សវនាការរបស់ក្រុមប្រឹក្សាគឺធ្វើឡើងជាសម្ងាត់ ដោយក្រុមប្រឹក្សាចាត់ទុកនូវរាល់កសិណ្យសាក្សី និងភស្តុតាងទាំងអស់ជាសម្ងាត់។[127] ក្រុមប្រឹក្សាត្រូវតែចេញសេចក្តីសម្រេច ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីទទួលបានសំណុំរឿង រួមទាំងពេលវេលាសម្រាប់សវនាការ និងស៊ើបអង្កេត ហើយពេលវេលានេះអាចពន្យាបាន លុះត្រាតែមានការយល់ព្រមពីភាគីទាំងពីរ។[128] ភាគីអាចជ្រើសរើស ទទួលយកភ្លាមៗនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្ទាប់ពីសេចក្តីបង្គាប់ចេញ ឬមានរយៈពេល៨ថ្ងៃនៃថ្ងៃប្រក្រតិទិនដើម្បីដាក់ការជំទាស់។[129]

ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានទទួលស្គាល់ថាជាស្ថាប័នឯករាជ្យ ដែលជាចំណុចសំខាន់មួយដែលធ្វើឲ្យក្រុមប្រឹក្សានេះទទួលបានកេរ្តិ៍ឈ្មោះ និងភាពជោគជ័យ។[130]

នៅក្នុងឆ្នាំ២០១៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានសំណុំរឿងប្រមាណ ២៨៥សំណុំរឿង (ដែលនេះគឺជាតួលេខខ្ពស់បំផុតនៅក្នុងប្រវត្តិសាស្ត្រស្ថាប័ននេះ) បើប្រៀបធៀបទៅនឹងសំណុំរឿងចំនួន ២៥៥ ដែលទទួលបាននៅក្នុងឆ្នាំ២០១២។[131] ភាគច្រើននៃសំណុំរឿងទទួលបាននៅក្នុងឆ្នាំ២០១៣ (ប្រមាណ ៨៥ភាគរយ) ទទួលបានមកពីវិស័យកាត់ដេរ និងស្បែកជើង ហើយចំនួននៅសេសសល់ទទួលបានពីវិស័យផលិតកម្ម (៤,២ ភាគរយ) វិស័យសេវាកម្ម (៥,១ភាគរយ) បដិសណ្ឋារកិច្ច និងទេសចរណ៍ (២,៥ ភាគរយ) សំណង់ (១,៥ ភាគរយ) និងវិស័យដ៏ទៃទៀត (២,១ ភាគរយ)។[132] ដោយយោងទៅលើ សំណុំរឿងដែលទទួលបានកាន់តែច្រើន ឯករាជ្យ-

---

[124] Prakas 099 , Arbitration Council, April 21, 2004.
[125] Cambodian Labour Law, Article 312.
[126] *Ibid*.
[127] *Ibid*.
[128] Cambodian Labour Law, Article 313 and Prakas 099, Clause 30.
[129] Prakas 099, Clauses 40 and 42.
[130] Van Noor, Hugo, S.Hwang, Hans, Bugeja, Kate, "Cambodia's Arbitration Council: Institution-building in a developing country," p. 15 (ILO-2011), Working Paper No. 24. Accessed from http://www.ilo.org/wcmsp5/groups/public/---ed_dialogue/---dialogue/documents/publication/wcms_166728.pdf. សុំមើលផងដែរ៖ ថ្មីៗនេះ ក្រុមប្រឹក្សានេះ ទទួលបាននូវការកោតសរសើរពីអ្នកជំនាញរបស់អង្គការពលកម្មពិភពលោក និងរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពីការផ្តល់នូវដំនោះស្រាយចំពោះវិវាទការងារ (http://thekhmerdaily.com/home/detail/23575)។
[131] http://www.arbitrationcouncil.org/en/about-us/statistics.
[132] *Ibid*.

ភាព និង កេរ្តិ៍ឈ្មោះរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្រុមប្រឹក្សានេះទំនងជា បន្តទទួលបាននូវការទុកចិត្តក្នុងការដោះស្រាយវិវាទការងារ។[133]

## V. **សេចក្តីសន្និដ្ឋាន**

ការចាប់ផ្តើមអនុវត្តប្រព័ន្ធដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការនៅកម្ពុជាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិគឺជាចំណុចសំខាន់មួយដើម្បីទទួលបាននូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា។ ទោះបីជាកង្វះខាតនូវហិរញ្ញវត្ថុ និងជំនួយសម្រាប់ថ្នាក់ក្រោមជាតិ សម្រាប់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ ជាពិសេស សម្រាប់មណ្ឌលសេវាកម្មយុត្តិធម៌ ជាបញ្ហាប្រឈមខ្លាំងក៏ដោយ ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងជំនួយពី UNDP គឺហាក់បីដូចជាអាចជួយជំរុញនូវគំនិតផ្តួចផ្តើមនេះឲ្យទទួលបានជោគជ័យ។ នៅថ្ងៃអនាគត បរិបទផ្នែកច្បាប់ដែលកំណត់ច្បាស់ពីតួនាទីរបស់គណៈកម្មាធិការដោះស្រាយទំនាស់ឃុំ-សង្កាត់ និងមណ្ឌលសេវាកម្មយុត្តិធម៌ រួមទាំងការទទួលយកនូវបទពិសោធន៍របស់អ្នកជំនាញនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រហែលជាអាចធ្វើឲ្យល្អប្រសើរឡើងនូវតួនាទីរបស់ស្ថាប័នទាំងពីរនេះ។

******************************

[133] Noor, Hwang, Bugeja, "Cambodia's Arbitration Council: Institution-building in a developing country", pp. 10-13.

# គន្ថនិទ្ទេស


Nomira, Toyohiro, Introduction to Civil Law ( JICA, 2014).

Cambodian Constitution

Law on the organization of courts

HAUERSTEIN, Kai, *"Aspects of Administrative Law and Its Reform in Cambodia"* in The Cambodian Administrative Law, ( Konrad-Adenauer-Stiftung, 2014)

YRIGOYEN FAJARDO, Raquel Z., Rady, Kong, and Phan, Sin, Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples. (UNDP-Ministry of Justice, 2005)

AUSTERMILLER, Steven, "*Cambodian Alternative Dispute Resolution*", in The Introduction to Law( Konrad-Adenauer-Stiftung, 2012).

Lewis, Melissa, and McCrimmon, Les, *"The Role of ADR Process in the Criminal Justice System: A view from Australia"* (Paper presented at At ALRAESA Conference, Entebbe, Uganda 4-8 September, 2005).

Goldberg, Jordan, *"Online Alternative Dispute Resolution and Why Law Schools should prepare Future Lawyers for the Online Forum,"* Peperdine Dispute Resolution Law Journal, 2014.

YRIGOYEN FAJARDO, Raquel Z., Rady, Kong, and Phan, Sin, Pathways to Justice: Access to Justice with a focus on the poor, women and indigenous peoples. (UNDP-Ministry of Justice, 2005)

Austermiller, Steven M., Alternative Dispute Resolution: Cambodia A Textbook of Essential Concept( USAID, 2010).

Paul, William G., *"Arbitration vs.Litigation in Energy Cases, Presentation"* (paper presented at the First Annual Energy Litigation Program, Hoston, Texas , November 7-8, 2002).

National Arbitration Forum., *"Business-to-Business: Mediation/Arbitration vs.Litigation*".

Phallack, Kong, *"Overview of the Cambodian Legal and Judicial System and Recent Efforts at Legal and Judicial Reform"*, in The Introduction to Cambodian Law, (Konrad-Adenauer-Stiftung, 2012).

Ramage, Ian, et al., Somroh Somruel & Violence Against Women, (Domrei Research and Consulting, 2008).

Hughes, Caroline, *"An investigation of Conflict Management in Cambodian Villages: A review of the literature with Suggestions for Future Research"*, (Cambodia Development Resource Institute (CDRI, 2001).

Luco, Fabienne, Between a tiger and a crocodile: Management of local conflicts, and anthropological approach to traditional and new practices (UNECSO, 2002).

Royal Decree on the Establishment of the Supreme Council of State Reform (1999), and Royal Decree on the Establishment of the Council of Judicial Reform (2000).

"Cambodia." Accessed February 4, 2015, http://www.wpro.who.int/countries/khm/en/.

Sub-Degree on Decentralization of Roles, Functions, and Power to Commune Councils (2002), Article 61.

Sub-decree No. 47 ANK.BK (May 31, 2002) 'On the Organization and Functioning of the Cadastral Commission'. Procedures were elaborated by Prakas No. 112 DNS/BrK (August 21, 2002) 'On the Guidelines and Procedures of the Cadastral Commission'.

Inter-Ministries Prakas No. 02 BRKN.03 in 2003 '*On Determination of Duty of the Court and Cadastral Commission Related to Land Disputes'*.

Popovic, Velibor, Melim-McLeod, Claudi, *"The Asia Pacific Rights and Justice Initiative: Cambodia Country Assessment."* (UNDP, 2009).

Ninh, Kim and Roger, Henke, *"Commune Council in Cambodia: A National Survey on their Functions and Performance, with a Special Focus on Conflict Resolution"* (The Asia Foundation, 2005).

Ministry of Women's Affair, *"Neary Ratanak IV: Five Years Strategic Plan For Gender Equality and Women's Empowerment 2014-2018"*

UNDP-*Cambodia Operation manual for commune dispute resolution committee* (CDRC), (UNDP-Cambodia 2010).

Ministry of Justice., Report to the Minister of the Ministry of Justice No. 02 STY/14 dated January 14, 2014.

Popovic, McLeod, *" The Asia Pacific Rights and Justice Initiative: Cambodia Country Assessment."*( UNDP, 2009), p. 13'; and McGrew, Laura and Doung, Virorth. *"Access to Justice Project in Cambodia: Final Evaluation Report.* (UNDP-2010).

Inter-ministerial Prakas No. 85Rbk/MOJ/MOI/06.

UNDP-*Cambodia Operation manual for the maison de la justice* (UNDP-Cambodia 2010).

Sub-Desgree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002.

Royal Kram on Law on Constitutional Amendment on Article 145 and 146 NS.RKM/0208/008/February 15, 2008.

Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans. May 22, 2008.

Prakas No 112 DNS/Brk on The Guidelines and Procedures of the Cadastral Commission.

GTZ-Cambodia and The world Bank., Toward Institutional Justice? A review of Cambodia's Cadastral Commission in Relation to Land Dispute Resolution ( GTZ-Cambodia and The world Bank, 2006).

Prakas on Power Delegation to Governor and Capital and Provincial Councilor 032 BRK.DNS/KSC dated January 21, 2010.

Circulation on the Procedure to implement the decision of Capital and Provincial Cadastral Commission dated January 21, 2010.

Sub-Degree on the Amendment on Article 5 and Article 28 of Sub Decree on Organisation and Functioning of the Cadastral Commission No 47 ANK.BK/May 31, 2002 (No. 34 ANK.BK/20 April 2006).

Prakas No 112 DNS/Brk on The Guidelines and Procedures of the Cadastral Commission.

GTZ-Cambodia and The world Bank., Toward Institutional Justice? A review of Cambodia's Cadastral Commission in Relation to Land Dispute Resolution.

Royal Degree on establishment of National Authority to Settle Land Dispute, NS/RKT/0206/097 February 26, 2006.

Inter-Ministries Prakas No. 02 BRKN.03 in 2003 'On Determination of Duty of the Court and Cadastral Commission Related to Land Disputes'.

Seng, Try, *"Land Conflict in Cambodia2001-2009."*

Prakas No. 099 , Arbitration Council, April 21, 2004.

Cambodian Labour Law

Noor, Hugo Van, S. Hwang, Hans, Bugeja, Kate, *"Cambodia's Arbitration Council: Institution-building in a developing country"* (ILO-2011) , Working Paper No. 24.

http://thekhmerdaily.com/home/detail/23575.

http://www.arbitrationcouncil.org/en/about-us/statistics.